# របាយការណ៍ប្រចាំឆ្នាំ ២០២៣








Contact us:
Email: info@afesip.org | Tel: +855 (0)61 601 601 / (0)12 888 840 | www.afesip.org

# មាតិកា

| | ទំព័រ |
| --- | --- |
| ស្ថាបនិក និងអគ្គនាយិកា | ៣ |
| អាហ្វេស៊ីបកម្ពុជា | ៤ |
| សកម្មភាពសំខាន់ៗប្រចាំខែ ឆ្នាំ២០២៣ | ៥ |
| ករណីជោគជ័យ | ៦ |
| របាយការណ៍សង្ខេប | ៧-៩ |
| អំពីការងាររបស់យើង | ១០-២៦ |
| បុគ្គលិក និងការគ្រប់គ្រងគម្រោង | ២៦-២៧ |
| ការបណ្តុះបណ្តាលកសាងសមត្ថភាពបុគ្គលិក និងផែនការសម្រាប់ឆ្នាំ២០២៤ | ២៨ |
| ក្រុមប្រឹក្សាភិបាល | ២៩ |
| សង្ខេបមូលនិធិទទួលបាន និងការចំណាយ | ៣០ |
| ម្ចាស់ជំនួយ | ៣១ |

## លោក-លោកស្រី នាងកញ្ញា ជាទីស្រឡាញ់ រាប់អាន!



នាងខ្ញុំមានសេចក្តីសោមនស្សរីករាយ សូមជម្រាបជូនរបាយការណ៍សកម្មភាពប្រចាំឆ្នាំ២០២៣ ដល់លោក លោកស្រី នាងកញ្ញាដូចខាងក្រោម៖ របាយការណ៍នេះបង្ហាញអំពីសមិទ្ធផលសម្រេចបាន បញ្ហាប្រឈម និងវឌ្ឍនភាពដែលយើងបានអនុវត្ត។

យើងមិនអាចសម្រេចលទ្ធផលបានដ៏ល្អប្រសើរនេះបែបនេះទេ ប្រសិនបើគ្មានការចូលរួមចំណែកពីលោក លោកស្រី នាងកញ្ញា ជាអ្នកគាំទ្រការងារយើងនោះទេ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត។ អង្គការអាហ្សេស៊ីបកម្ពុជា យើងមានមោទនភាព ចំពោះតម្លាភាព និងគុណតម្លៃ នៃការធ្វើប្រតិបត្តិការរបស់យើងចំពោះម្ចាស់ជំនួយ និងអ្នកគាំទ្ររបស់យើង។ នៅក្នុងរបាយការណ៍នេះ បានបង្ហាញពិស្តារអំពីសកម្មភាពការងាររបស់យើងពេញមួយឆ្នាំ២០២៣ ក្នុងគោលបំណងបង្ហាញជូននូវវឌ្ឍនភាព យើងបានធ្វើឱ្យមានឥទ្ធិពលវិជ្ជមាន លើជីវិតកុមារីជាច្រើននាក់ ដែលយើងបានជួយ និងក្រុមគ្រួសាររបស់ពួកគាត់ នៅក្នុងប្រទេសកម្ពុជា។

២០២៣ ជាឆ្នាំជោគជ័យមួយទៀត របស់អង្គការ អាហ្សេស៊ីប កម្ពុជា ព្រោះយើងបានប្រារព្ធខួបគម្រប់១០ឆ្នាំ នៃការបើកប្រតិបត្តិការឡើងវិញ របស់អង្គការដ៏សែនលំបាកនារយៈពេល១០ឆ្នាំកន្លងទៅ។ របាយការណ៍ឆ្នាំ២០២៣នេះ លោក លោកស្រី នាងកញ្ញា នឹងបានអានអំពីការបន្តភាពភាពជោគជ័យនៃការអនុវត្តបណ្តាកម្មវិធីដ៏យូអង្វែងរបស់យើង ក្នុងការបន្តជួយជីវិតជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគាត់ជាបន្តបន្ទាប់ ករណីជោគជ័យរបស់អ្នកទទួលផលពីគម្រោងរបស់យើង ទឹកចិត្តសប្បុរសរបស់សហគមន៍យើង ជាមួយនឹងការអភិវឌ្ឍន៍ថ្មីៗរបស់យើង ជារួមមានសកម្មភាពកម្មវិធីសិប្បកម្ម ការកែលម្អបណ្ណាល័យ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធមណ្ឌល-បន្ទប់ថែទាំសុខភាព និងភាពជោគជ័យនៃការតស៊ូមតិរបស់យើងមិនអនុញ្ញាតឱ្យកុមាររងគ្រោះអាយុក្រោម១០ឆ្នាំចូលរួមសវនការប្រឈមជាមួយជនជាប់ចោទនៅតុលាការ។

ករណីជោគជ័យដែលយើងលើកមកបង្ហាញនៅក្នុងរបាយការណ៍នេះ គឺយើងមិនអាចសម្រេចបាននោះទេ ប្រសិនបើគ្មានការចូលរួមយ៉ាងសកម្មពីបណ្តាបុគ្គលិក បុគ្គលិកស្ម័គ្រចិត្ត សមាជិកក្រុមប្រឹក្សាភិបាល សប្បុរសជន និងដៃគូសហគមន៍ ជាពិសេសការគាំទ្រពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាបន្តបន្ទាប់រហូតមក។ នាងខ្ញុំផ្ទាល់សូមថ្លែងអំណរគុណដល់លោក លោកស្រី នាងកញ្ញា នូវការលះបង់ពេលវេលា ការយកចិត្តទុកដាក់ និងការជួយឧបត្ថម្ភគាំទ្រនាឆ្នាំកន្លងមកនេះ។ អ្នកទាំងអស់គ្នាអស្ចារ្យខ្លាំងណាស់ ហើយនាងខ្ញុំមានមោទនភាពខ្លាំងណាស់ ដែលបានរួមការងារដ៏ល្អមួយនេះជាមួយអ្នកទាំងអស់គ្នា។ នាងខ្ញុំសូមអរគុណ ដល់លោក លោកស្រី នាងកញ្ញា ដែលបានអានរបាយការណ៍សកម្មភាពឆ្នាំ២០២៣នេះ ហើយនាងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាលោក លោកស្រី នាងកញ្ញា នៅបន្តជួយការងាររបស់យើងបន្តទៀត តាមលទ្ធភាពរបស់លោក លោកស្រី នាងកញ្ញា ដើម្បីលុបបំបាត់ នូវរាល់ទម្រង់រំលោភបំពានផ្សេងៗ លើកុមារនៅក្នុងសហគមន៍យើង។ យើងសាមគ្គីគ្នា នៅថ្ងៃនេះ ធ្វើជាអ្នកការពារសហគមន៍ដ៏រឹងមាំ ហើយយើងក៏អាចធ្វើឱ្យសហគមន៍យើងបានល្អប្រសើរឡើងនៅថ្ងៃស្អែក។

ដោយក្តីរាប់អានដ៏ស្មោះអំពីនាងខ្ញុំ

**ស្ថាបនិក និងអគ្គនាយិកា**

**លោកស្រីម៉ម សុម៉ាលី**

# អំពី អាហ្វេស៊ីប កម្ពុជា

**អង្គការ អាហ្វេស៊ីប កម្ពុជា** បានបង្កើតឡើងនៅឆ្នាំ១៩៩៦ ដោយលោកស្រី**ម៉ម សុម៉ាលី** លោកស្រីជាអតីតជនរងគ្រោះដោយការជួញដូរ ក្នុងគោលបំណងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

**ចក្ខុវិស័យ** ជាពិភពលោកមួយដែលកុមារមានសុវត្ថិភាពពីទាសភាព។

**ទិសដៅអង្គការ** ផ្តល់ការថែទាំ និងធានាបាននូវសិទ្ធិរបស់យុវនារី-កុមារីរងគ្រោះ និងងាយរងគ្រោះ ដោយអំពើទាសភាព តាមរយៈការស្តារនីតិសម្បទា ការអប់រំ បណ្តុះបណ្តាល និងសមាហរណកម្មដោយជោគជ័យ ត្រឡប់ទៅសង្គមវិញ ដោយឯករាជ្យភាពហិរញ្ញវត្ថុ និរន្តរភាព និងភាពថ្លៃថ្នូរ។ យើងអនុវត្តការងារនេះ ដោយជួយជ្រោមជ្រែង និងបង្ហាត់បង្រៀនពួកគាត់ អំពីឯករាជ្យភាពហិរញ្ញវត្ថុ តាមរយៈនិរន្តភាពមុខរបរ។ បន្ទាប់មកយើងស្វាគមន៍ លើកទឹកចិត្តឱ្យពួកគាត់ក្លាយជាផ្នែកមួយរបស់បណ្តាញលើកកម្ពស់អតីតៈជនរងគ្រោះ ។

**ក្រុមគោលដៅ** កុមារីជនរងគ្រោះ និងងាយរងគ្រោះ ដោយការជួញដូរ រំលោភបំពាន និង កេងប្រវ័ញ្ចផ្លូវភេទ។

## កម្មវិធីយើង



# សកម្មភាពប្រចាំខែសំខាន់ ៗ ឆ្នាំ២០២៣

## មករា នាយករដ្ឋមន្ត្រី សម្ពោធដាក់ឱ្យប្រើប្រាស់អាគារថ្មី

**សម្ដេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេច កិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ស្ត្រីទី១ នៃព្រះរាជាណាចក្រកម្ពុជា** បានសម្ពោធដាក់ឱ្យប្រើប្រាស់អាគារថ្មីជាផ្លូវការ នៅមណ្ឌលទំុឌី ដែលលោកបានសាងសង់ ជូនអង្គការ អាហ្វេស៊ីប កម្ពុជា។

## កុម្ភៈ នីតិវិធីគាំពារកុមាររងគ្រោះបានប្រសើរឡើង

ក្នុងឱកាសសម្ពោធដាក់ឱ្យប្រើប្រាស់មណ្ឌលទំុឌី **សម្ដេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃ**ព្រះរាជាណាចក្រកម្ពុជា** បានយល់ព្រមលើសំណើរបស់លោកស្រី**ស្ថាបនិកនិងអគ្គនាយិកា ម៉ម សុម៉ាលី** អង្គការ អាហ្វេស៊ីប កម្ពុជា មិនឱ្យកុមាររងគ្រោះអាយុក្រោម១០ឆ្នាំចូលសវនាការជំរះក្តីប្រឈមជាមួយជនជាប់ចោទនៅតុលាការ។

## មិនា អតីតជនរងគ្រោះជាផ្នែកមួយនៃដំណោះស្រាយដ៏ល្អ

ផ្នែកមួយនៃការងាររបស់យើង គឺលើកកម្ពស់សមភាពយេនឌ័រ និងលើកកម្ពស់អតីតជនរងគ្រោះឱ្យក្លាយជាផ្នែកមួយនៃដំណោះស្រាយ។ ៨៤%នៃបុគ្គលិកស្ត្រីរបស់យើងជាអតីតជនរងគ្រោះ ពួកគាត់កាន់តួនាទីជាមេដឹកនាំ និងជាបុគ្គលិកជាន់ខ្ពស់។

## មេសា ការពារប្រសើរជាងព្យាបាល

យើងបានរៀបចំយុទ្ធនាការផ្សព្វផ្សាយមួយសប្តាហ៍ តាមបណ្តាញសង្គម ស្តីអំពី **#ភាពញញឹមនៃកុមារ #គ្រួសារកក់ក្តៅ** នៅក្នុងឱកាសខួបកំណើតលោកស្រីស្ថាបនិក និងអគ្គនាយិកា **ម៉ម សុម៉ាលី**។ គោលបំណងនៃយុទ្ធនាការនេះ គឺដើម្បីលើកកម្ពស់ និងបញ្ជ្រាបការយល់ដឹង អំពីការស្រឡាញ់គ្រួសារ ការយកចិត្តទុកដាក់ថែទាំកូនៗ និងការចេះជួយយកអាសាអ្នកដ៏ទៃក្នុងគ្រាលំបាក។

## ឧសភា យើងមានតម្លាភាព និងគណនេយ្យភាព

ជាទូទៅយើងធ្វើសវនកម្មហិរញ្ញវត្ថុបំណាច់ឆ្នាំ២០២២ ដោយប្រើសេវាកម្មពីក្រុមហ៊ុនសវនកម្មKPMG រៀងរាល់ខែមេសា។ នេះជាការត្រួតពិនិត្យ និងវាយតម្លៃពីភាពស្មោះត្រង់នៃកំណត់ត្រាប្រតិបត្តិការ និងភាពត្រឹមត្រូវនៃការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ។

## មិថុនា យើងប្រារព្ធនិងអបអរសាទរទិវាសិទ្ធិកុមារដល់កុមារទាំងអស់

យើងបានប្រារព្ធទិវាសិទ្ធិកុមារអន្តរជាតិលើកទី៧៤ ជូនកុមារីនៅមណ្ឌលទំុឌី ក្នុងគោលបំណង លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិមូលដ្ឋានទាំង៤របស់កុមារគឺ សិទ្ធរស់រានមានជីវិត សិទ្ធិទទួលការគាំពារ សិទ្ធិទទួលការអភិវឌ្ឍន៍ និងសិទ្ធិចូលរួម។

## កក្កដា ថែទាំសុខភាពផ្លូវចិត្តបុគ្គលិក និងសុខមាលភាពពួកគេ

យើងបានផ្តល់វគ្គបណ្តុះបណ្តាលកសាងសមត្ថភាពបុគ្គលិករយៈពេល៣ថ្ងៃ អំពីសុខភាពផ្លូវចិត្តបឋម ដល់បុគ្គលិកចំនួន២៦នាក់ ផ្តល់ដោយគ្រូឧទ្ទេសនាមអញ្ជើញមកពីCTRO ក្នុងទិសដៅផ្តល់បច្ចេកទេសស្វ័យថែទាំជូនបុគ្គលិក ដើម្បីស្វ័យថែទាំសុខភាពផ្លូវចិត្ត ក្នុងគោលបំណងលើកកម្ពស់ទំនាក់ទំនងវិជ្ជមាន នៅកន្លែងការងារ និងនៅផ្ទះ ជាប្រយោជន៍ជំរុញគុណភាព និងប្រសិទ្ធិភាពការងារ។

## សីហា បរិក្ខាច្រើន បង្កើនគុណភាពសេវាកម្ម

យើងបានបង្កើនគុណភាព និងប្រសិទ្ធិភាព ការថែទាំសុខភាពទូទៅ ដល់យុវនារី និងកុមារីដោយបានបំពាក់ម៉ាស៊ីនពិនិត្យឈាម (bio-chemistry and hem atology) និងបរិក្ខាថែទាំសុខភាពមួយចំនួនទៀត ក្នុងបន្ទប់ថែទាំសុខភាព។

## កញ្ញា សកម្មភាពសិល្បៈជាផ្នែក១នៃការព្យាបាលសុខភាពផ្លូវចិត្ត

យើងបានបង្កើតកម្មវិធីហត្ថកម្ម សម្រាប់បង្ហាត់បង្រៀនសកម្មភាពសិប្បកម្មផ្សេងៗ ដល់យុវនារី-កុមារី ព្រោះថាវាជាផ្នែកមួយនៃការព្យាបាលដំបូង ក្នុងការស្តារការគោរព និងឱ្យតម្លៃខ្លួនឯង និងការកសាងជំនឿចិត្តឡើងវិញ។

## តុលា យើងជាដៃគូមានគណនេយ្យភាព តម្លាភាព និងទុកចិត្តបំផុត

យើងបានចូលជាសមាជិក Give2Asia ជាស្ពាន ដែលជាវេទិកាក្រៅប្រទេសដ៏ទុកចិត្តមួយ សម្រាប់ឱ្យយើងចែករំលែកលទ្ធផលការងារ និងទទួលថវិកាពីម្ចាស់មូលនិធិអន្តរជាតិបាន។

## វិច្ឆិកា ប្រតិបត្តិតាមបទដ្ឋានអតិបរិមា

ការិយាល័យសង្គមកិច្ចខណ្ឌបានចុះមកធ្វើអធិការកិច្ចប្រចាំឆ្នាំអំពីសេវាជនរងគ្រោះនៅមណ្ឌលទំុឌី ដើម្បីពិនិត្យមើល ថាតើអង្គការ អាហ្វេស៊ីប កម្ពុជា បានអនុវត្តតាមបទដ្ឋានអតិបរិមាត្រឹមត្រូវដែរឬទេ។

## ធ្នូ ពិធីប្រគល់វិញ្ញាបនបត្រ និងបណ្ណសសើរ

យើងបានរៀបចំពិធីប្រគល់វិញ្ញាបនបត្របញ្ចប់ការសិក្សា និងការលើកទឹកចិត្តដល់អាហាររូបករណ៍សកលវិទ្យាល័យដែលបានបញ្ចប់ការសិក្សាបរិញ្ញាបត្រនិងបរិញ្ញាបត្រជាន់ខ្ពស់ ដោយជោគជ័យចំនួន១៥នាក់។ ក្នុងឱកាសនោះ យើងក៏បានប្រគល់មេដាយកិត្តិយសជូនក្រុមប្រឹក្សាភិបាល បុគ្គលិក និងកុមារីឆ្នើម។

# ករណីជោគជ័យ

**សែម ស្រីធី** (KC-0040) ឥឡូវនេះមានអាយុ១៩ឆ្នាំ មកពីខេត្តកំពង់ស្ពឺ ជាអតីតកុមារីរងគ្រោះ ដោយការរំលោភបំពាន ដែលប្រព្រឹត្តឡើងដោយសាច់ញាតិ។ ជនសង្ស័យមិនត្រូវបានចាប់ខ្លួនទេ។ នាងបានបញ្ជូនមកទទួលសេវានៅអង្គការ អាហ្វេស៊ីប នៅខែកញ្ញា ឆ្នាំ២០០៩។ នាងបានទទួលការថែទាំ និងឧបត្ថម្ភពីអង្គការ អាហ្វេស៊ីប រយៈពេល ១៤ឆ្នាំ ដោយបានស្នាក់នៅក្នុងមណ្ឌលរយៈពេល៦ឆ្នាំ។



នាងបានប្រឡងបញ្ចប់មធ្យមសិក្សាទុតិយភូមិថ្នាក់ទី១២ នៅឆ្នាំ២០១៩ ហើយបានទទួលអាហារូបករណ៍ឧត្តមសិក្សា ពីអង្គការ អាហ្វេស៊ីប បន្តការសិក្សានៅសកលវិទ្យាល័យ។ នាងសិក្សាបរិញ្ញាបត្រផ្នែកច្បាប់នៅសកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (RULE) នៅទីក្រុងភ្នំពេញ។ នាងចំណាយពេលសិក្សា៤ឆ្នាំ ហើយបានបញ្ចប់ការសិក្សាបរិញ្ញាបត្រផ្នែកច្បាប់ដោយជោគជ័យ នៅខែតុលា ឆ្នាំ២០២៣ ។

យើងបានសមាហរណកម្មនាង ជាមួយការឧបត្ថម្ភការងារ នៅក្រុមហ៊ុនច្បាប់មួយនៅភ្នំពេញ មានតួនាទីជាជំនួយការមេធាវី នៅខែធ្នូ ឆ្នាំ២០២៣។ នាងបានប្រើប្រាស់ជំនាញនាងបានសិក្សា អាចជួយឱ្យនាងឆ្លងផុត ពីបន្ទាត់ក្រីក្រ តាមរយៈការទទួលបានប្រាក់ចំណូលទៀងទាត់ ផ្គត់ផ្គង់ខ្លួននាង និងក្រុមគ្រួសារ។

**ខែត សុយ៉ា** (PP-3347) ឥឡូវនេះមានអាយុ២០ឆ្នាំ ជាអតីតកុមារីរងគ្រោះ ដោយការរំលោភបំពាន ដែលប្រព្រឹត្តឡើងដោយអ្នកជិតខាងអាយុ៥៩ឆ្នាំ កាលពីនាងមានអាយុ ១២ឆ្នាំ។ ជនល្មើសត្រូវបានចាប់ខ្លួន និងផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល១០ឆ្នាំ។



មន្ទីរសង្គមកិច្ចខេត្តកំពង់ស្ពឺបាននាំនាងមកទទួលសេវានៅអង្គការអាហ្វេស៊ីបនៅខែតុលាឆ្នាំ ២០១៥។ នាងបានទទួលការថែទាំ និងឧបត្ថម្ភ ពីអង្គការ អាហ្វេស៊ីប រយៈពេល៨ឆ្នាំ។ នាងបានប្រឡងមធ្យមសិក្សាទុតិយភូមិ នៅខែធ្នូ ឆ្នាំ២០២០ ហើយបានទទួលអាហារូបករណ៍ឧត្តមសិក្សា ពីអង្គការ អាហ្វេស៊ីប បន្តការសិក្សានៅសកលវិទ្យាល័យ។ នៅថ្ងៃអនាគតនាងចង់ធ្វើជាមេធាវី ។

នាងកំពុងសិក្សាបរិញ្ញាបត្រផ្នែកច្បាប់ ឆមាសទី២ ឆ្នាំទី៤ នៅសកលវិទ្យាល័យ វេសស្ទើន (Western) ។ នាងកំពុងហាត់ការក្នុងកម្មវិធីគាំពារនីតិកម្ម ដោយមានការទទួលខុសត្រូវចំបងៗ លើការចុះទទួលកុមារីរងគ្រោះចូលមណ្ឌល ជូនកុមារីរងគ្រោះចូលឆ្លើយបំភ្លឺ និងចូលរួមសវនាការជំរះក្តីនៅតុលាការ។ នាងកំពុងប្រើប្រាស់ជំនាញ នាងសិក្សាជួយដល់កុមារីរងគ្រោះដ៏ទៃទៀតតាមរយៈប្រព័ន្ធយុត្តិធម៌។

**នាង ស្រីម៉ាច** (PP-1898) ឥឡូវនេះមានអាយុ២៣ឆ្នាំ នាងនិងបងស្រីរបស់នាងជាអតីតកុមារីរងគ្រោះ ដោយការជួញដូរ និងការរំលោភបំពាន កាលពីនាងមានអាយុ៤ឆ្នាំ។ មន្ទីរសង្គមកិច្ចខេត្តបានបញ្ជូននាង និងបងស្រីរបស់នាងមកទទួលសេវានៅ អង្គការ អាហ្វេស៊ីប នៅឆ្នាំ២០០៤។ នាងបានទទួលការថែទាំ និងឧបត្ថម្ភ ពីអង្គការ អាហ្វេស៊ីបរយៈពេលជាង១៩ឆ្នាំ។



ក្តីសុបិន្តរបស់នាង នាពេលអនាគត ចង់ធ្វើជាប៉ូលីស និងអ្នករាំបាំប្រពៃណី។ នាងបានប្រឡងមធ្យមសិក្សាទុតិយភូមិ នៅខែសីហា ឆ្នាំ២០១៩ ហើយបានទទួលអាហារូបករណ៍ឧត្តមសិក្សា ពីអង្គការ អាហ្វេស៊ីប បន្តការសិក្សានៅសកលវិទ្យាល័យ។ នាងសិក្សាបរិញ្ញាបត្រផ្នែកទីផ្សារ និងទំនាក់ទំនង នៅសកលវិទ្យាល័យ វេសស្ទើន (Western) រយៈពេល៤ឆ្នាំកន្លះ នាងបានបញ្ចប់ការសិក្សាដោយជោគជ័យនៅក្នុងឆ្នាំ២០១២៣។

យើងបានសមាហរណកម្មនាង ជាមួយការឧបត្ថម្ភការងារ នៅក្រុមហ៊ុនប៊ីហ្គើឃីង មានតួនាទីជាបុគ្គលិកផ្នែកទីផ្សារ នៅខែធ្នូ ឆ្នាំ២០២៣។

**ដេត គាំងហ៊ួយ** (PP-3526) ឥឡូវនេះមានអាយុ១៦ឆ្នាំ នាងជាអតីតកុមារីរងគ្រោះ ដោយការរំលោភបំពាន មន្ទីរសង្គមកិច្ចខេត្ត បានបញ្ជូននាង និងបងប្អូនរបស់នាង២នាក់ទៀត ជាអតីតកុមារីរងគ្រោះដោយការរំលោភបំពាន ដែរនោះ មកទទួលជម្រកសុវត្ថិភាព និងការថែទាំនៅអង្គការ អាហ្វេស៊ីប នៅខែមិនា ឆ្នាំ២០២២ ជនសង្ស័យរត់គេចខ្លួន។



នាងជាសិស្សអាហារូបករណ៍ ផ្នែកជំនាញវិជ្ជាជីវៈ ចាប់ផ្តើមសិក្សាជំនាញសម្អាងកាយ នៅខែមិថុនា ឆ្នាំ២០២២ និងបានបញ្ចប់ការសិក្សាដោយជោគជ័យលើមុខជំនាញដែលនាងបានជ្រើសរើស នៅខែកញ្ញា ឆ្នាំ២០២៣។ នាងបានទទួលការថែទាំ និងឧបត្ថម្ភ ពីអង្គការ អាហ្វេស៊ីប រយៈពេល២ឆ្នាំ។

យើងបានធ្វើសមារណកម្មនាង ត្រឡប់ទៅគ្រួសារវិញ ជាមួយការឧបត្ថម្ភមុខរបរខ្នាតតូច នូវសម្ភារៈអ៊ុតសក់និងសម្អាងកាយ១ឈុត ដើម្បីបើកហាងសាឡនតូចមួយនៅស្រុកកំណើតនៅខែកញ្ញាឆ្នាំ២០២៣ ដើម្បីប្រើប្រាស់ជំនាញនាងបានសិក្សារៀនសូត្ររកប្រាក់ចំណូលទ្រទ្រង់ជីវភាពប្រចាំថ្ងៃរបស់នាង។

# របាយការណ៍សង្ខេប

ស្ទើរគ្រប់សូចនាករពឹងទុកកម្មវិធីនីមួយៗ ដែលយើងបានដាក់ចេញ សម្រាប់ឆ្នាំ២០២៣ អនុវត្តសម្រេចបានលទ្ធផលល្អប្រសើរ ថ្វីបើយើងជួបបញ្ហាប្រឈមខ្លះៗ។ កម្មវិធីខ្លះសម្រេចបានលទ្ធផល លើសពីការពឹងទុកនៃផែនការរបស់យើងក្នុងរយៈពេល១២ខែកន្លងមកនេះ។

កុមារីចំនួន៩៤នាក់ បានទទួលការស្នាក់នៅដោយសុវត្ថិភាព អាហារូបត្ថម្ភ ការថែទាំសុខភាព ការពិគ្រោះយោបល់ចិត្តសង្គម ជំនួយនីតិកម្ម (៨៣នាក់)ការអប់រំ និងបណ្តុះបណ្តាល ភាសាអង់គ្លេស កុំព្យូទ័រ ខណៈកំពុងស្នាក់នៅក្នុងមណ្ឌលទុំឌី។

កុមារីចំនួន១៩១នាក់ បានទទួលអាហារូបករណ៍ក្រោមឧត្តមសិក្សា ឧត្តមសិក្សា និង ជំនាញវិជ្ជាជីវៈដូចក្នុងតារាងបង្ហាញជូនខាងក្រោមនេះ៖

| ស្ថិតិសង្ខេបកុមារីទទួលការថែទាំ&ឧបត្ថម្ភ | ២០២៣ | | ធ្នូ២០២៣ - មិថុនា២០២៤ | |
|---|---|---|---|---|
| | សរុប | កំណត់សម្គាល់ | សរុប | សម្គាល់ |
| កុមារីទទួលការថែទាំក្នុងមណ្ឌល | ៩៤ | (៦២នាក់ចុងគ្រា២០២២ និង ៣២នាក់ចូលថ្មី | ៧១ | (២៣នាក់ចេញពីមណ្ឌល) |
| សិស្សអាហារូបករណ៍ក្រោមឧត្តមសិក្សា(ក្នុងម.ណ) | ៨៣ | (៦២នាក់ចុងគ្រា២០២២ និង២១នាក់ចូលរៀនថ្មី) | ៧២ | (១០នាក់អាហារូបករណ៍ក្រោមឧត្តមសិក្សា និង១នាក់ជាប់មធ្យមសិក្សាទុតិយភូមិ) |
| សិស្សអាហារូបករណ៍ជំនាញវិជ្ជាជីវៈ | ៩ | (៥នាក់ចុងគ្រា២០២២ ៤នាក់ចូលរៀនថ្មី) | ៤ | (៥នាក់បញ្ចប់ការសិក្សាជំនាញ) |
| សិស្សអាហារូបករណ៍ក្រោមឧត្តមសិក្សា(ក្រៅម.ណ) | ៧៨ | (៦២នាក់ចុងគ្រា២០២២ និង១៦នាក់ចូលរៀនថ្មី) | ៦៦ | (៣នាក់ជាប់មធ្យមសិក្សាទុតិយភូមិនិង៩នាក់បោះបង់) |
| និស្សិតអាហារូបករណ៍ឧត្តមសិក្សាសកលវិទ្យាល័យ | ២១ | (១០នាក់ចុងគ្រា២០២២ និង១១នាក់ចូលរៀនថ្មី) | ១៦ | (៥នាក់បានបញ្ចប់ការសិក្សា) |
| សមាហរណកម្មជាមួយការងារ និងមុខរបរ | ១៦ | | ១៦ | ក្នុងនោះ៣មុខរបខ្នាតតូច |
| សមាជិកបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ | ៥៩ | (៤៥នាក់ចុងគ្រា២០២២ និង១៤នាក់សមាជិកថ្មី) | ៥៩ | |
| ករណីសមាហរណកម្មស្ថិតក្រោមការតាមដានបន្ត | ១៧៩ | (១៥៣នាក់ចុងគ្រា២០២២ និង២៦នាក់ថ្មី) | ១៧៩ | |
| សរុប | ៥៣៩ | | ៤៨៣ | |



# ការកសាងហេដ្ឋារចនាសម្ព័ន្ធ

- យើងបានធ្វើរបងដែកជុំវិញរានហាលខាងក្រោយបន្ទប់គេងរបស់កុមារីចំនួន១៦បន្ទប់(២១៨,២៤ម៉ែត្រក្រឡា) នៅជាន់ទី១ ដើម្បីពង្រឹងប្រព័ន្ធការពារសុវត្ថិភាពដល់កុមារី អំឡុងស្នាក់នៅស្តារនីតិសម្បទានៅក្នុងមណ្ឌលទុំឌី។

- ដើម្បីផ្តល់សុខសុវត្ថិភាព និងបរិស្ថានល្អ យើងបានជួសជុលបន្ទប់កុមារីគេងចំនួន៦បន្ទប់ ដែលលិចជ្រាបទឹក នៅលើបន្ទប់ថែទាំសុខភាព និងបន្ទប់ប្រជុំរួម។

- ដើម្បីពង្រឹងប្រព័ន្ធសន្តិសុខនិងសុវត្ថិភាពដល់កុមារីនៅក្នុងមណ្ឌល យើងបានបំពាក់បន្ថែមកាមេរ៉ាសុវត្ថិភាព២គ្រឿងក្នុងបន្ទប់បណ្ណាល័យ ២គ្រឿងនៅក្នុងបន្ទប់ពិគ្រោះយោបល់ចិត្តសាស្ត្រ ១គ្រឿងនៅក្នុងថ្នាក់បង្រៀនភាសាអង់គ្លេស ១គ្រឿងនៅក្នុងថ្នាក់បង្រៀនកុំព្យូទ័រ ២គ្រឿងនៅក្នុងបន្ទប់ថែទាំសុខភាព និងប្តូរផ្ទាំងបញ្ចាំងកាមេរ៉ា១គ្រឿង។

- ផ្តល់សកម្មភាពនៃការព្យាបាលឱ្យបានច្រើន យើងបានអភិវឌ្ឍ និងកែលម្អបន្ទប់សិប្បកម្មមួយនៅជាន់ទី២ សម្រាប់បុគ្គលិកថែទាំបង្រៀនសកម្មភាពសិប្បកម្មផ្សេងៗដល់កុមារី។ សកម្មភាពសិប្បកម្មនេះ វាជាផ្នែកមួយនៃដំណើរការព្យាបាលដល់កុមារី ក្នុងសាងការផ្តោតអារម្មណ៍ ធ្វើឱ្យមានភាពជឿជាក់ និងទំនុកចិត្តលើខ្លួនឯងឡើងវិញ។

- ដើម្បីសន្សំសំចៃថ្លៃធ្វើដំណើរនិងថ្លៃធ្វើតេស្តឈាម យើងបានដំឡើងម៉ាស៊ីនពិនិត្យឈាមចំនួន២គ្រឿង(bio-chemistry និងhematology) បំពាក់បរិក្ខាថែទាំសុខភាពផ្សេងៗ និងម៉ាស៊ីនព្រីន្ទពហុមុខងារ(ព្រីន្ទ ស្កាន ថតចម្លង)១គ្រឿងនៅក្នុងបន្ទប់ថែទាំសុខភាព នៅមណ្ឌលទុំឌី។ ការបំពាក់សម្ភារៈ និងបរិក្ខាពេទ្យទាំងអស់នេះ អាចជួយឱ្យយើងចំណេញពេលវេលា សន្សំសំចៃថ្លៃធ្វើដំណើរ និងថ្លៃតេស្តឈាមកុមារីនៅតាមបណ្តាមន្ទីរពេទ្យ និងគ្លីនិចខាងក្រៅ ព្រោះថា១០០%នៃកុមារីដែលទទួលចូលអង្គការ អាហ្វេស៊ីប កម្ពុជា ចាំបាច់ត្រូវការធ្វើតេស្តឈាមដើម្បីធ្វើរោគវិនិច្ឆ័យឱ្យមានច្បាស់លាស់ និងការព្យាបាលឱ្យបានត្រឹមត្រូវ។

- ដើម្បីសុខសុវត្ថិភាពកុមារីនិងបុគ្គលិក យើងបានធ្វើដំបូលផ្ទះបាយថ្មី ព្រោះភ្លៀងមកម្តងៗតែងតែលិចទឹកពីដំបូលចុះមកយ៉ាងខ្លាំង បានវាយបន្ទប់ទឹក២បន្ទប់នៅក្បែផ្ទះចោលដើម្បីឱ្យផ្ទៃផ្ទះបាយបានធំទូលាយ និងដើម្បីការពារការលិចទឹកនៅរដូវវស្សាយើងបានរៀបចំធ្វើប្រព័ន្ធបង្ហូរទឹកនៅក្នុងបរិវេណមណ្ឌល ធ្វើប្រព័ន្ធបូមទឹកស្វ័យប្រវត្តិ និងធ្វើផ្លូវទួលនៅច្រកទ្វាធំមុខមណ្ឌលការពារកុំឱ្យទឹកហូរពីផ្លូវធំចូលក្នុងមណ្ឌលនៅពេលភ្លៀង។

- យើងបានរៀបចំកែលម្អបណ្ណាល័យ និងដាក់ធនធានបន្ថែម ដូចជាសៀវភៅអានភាសាខ្មែរចំនួន២០០ក្បាលសម្រាប់កុមារីអាន សាឡុង១ឈុត តុនិងកៅអីសម្រាប់អាន១ឈុត ធ្នើដាក់សៀវភៅមុខពីរ។ល។



# ពិធីប្រគល់វិញ្ញាបនបត្រនិងបណ្ណសរសើរ

យើងបានប្រារព្ធពីធីប្រគល់វិញ្ញាបនបត្រ បណ្ណសសើរ និងខួប១០នៃការធ្វើប្រតិបត្តិការឡើងវិញ របស់អង្គការ អាហ្វេស៊ីប កម្ពុជា ក្នុងកាលទេសៈដ៏លំបាក ថ្លែងអំណរគុណ និងចែករំលែកសេចក្តីរីករាយ អំពីជោគជ័យរបស់យើង ដល់បណ្តាដៃគូពាក់ព័ន្ធ បុគ្គលិក និងអ្នកទទួលផលពី គម្រោងរបស់យើង ដោយយើងបានផ្តល់វិញ្ញាបនបត្រ និងមេដាយជូននិស្សិតឧត្តមសិក្សាអាហារូបករណ៍ សកលវិទ្យាល័យ៣ជំនាន់ចំនួន១៥ នាក់ សិស្សពូកែចំណេះដឹងទូទៅសិក្សានៅសាលារដ្ឋចំនួន២នាក់ សិស្សពូកែប្រចាំថ្នាក់ភាសាអង់គ្លេស និងកុំព្យូទ័រចំនួន១៧នាក់ សមាជិក ប្រធានក្រុមអ្នកដឹកនាំក្រុមចំនួន៥នាក់ បណ្ណសសើរដល់បុគ្គលិកបានបម្រើការងារក្នុងអង្គការអាហ្វេស៊ីបកម្ពុជាពី១០ឆ្នាំឡើងទៅចំនួន១៥ នាក់ នាយកសាលាចំនួន២នាក់ មេដាយដល់បុគ្គលិកជាអតីតជនរងគ្រោះបានលះបង់ពេលវេលាទាំងថ្ងៃឈប់សម្រាក និងចុងសប្តាហ៍ដើម្បី បំរើការងារចំនួន៩នាក់ មេដាយវីរៈនារីជូនស្ថាបនិក និងអគ្គនាយិកា ម៉ម សុម៉ាលី ជូនមេដាយកិត្តិយសក្រុមប្រឹក្សាភិបាល លោកឃ្លូដ ហិលឌែនប្រេនដ៏ ជាប្រធានក្រុមប្រឹក្សាភិបាល អគ្គនាយករងមូនិធិសូលីណា និងជាស្ថាបនិកក្រុមហ៊ុនវ៉ុនី&វ៉ុនី ហ្សា កញ្ញាអាណាលីន្ន ម៉ាខ័ដ ជា សមាជិកក្រុមប្រឹក្សាភិបាល តារាសម្តែងហូលីវ៉ូដសកម្មជនសិទ្ធិមនុស្ស និងស្ថាបនិកព្យុះស្នេហ៍ វេជ្ជ.ឌេវ៉ិដ យុគ (នាយកប្រតិបត្តិESG)ជាអតីត សមាជិកក្រុមប្រឹក្សាភិបាល លោកឆានឌូ ប៊ីនឌី ជាសមាជិកក្រុមប្រឹក្សាភិបាល ប្រធានប្រតិបត្តិករធនាគារទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី និង សមាជិកជាក្រុមប្រឹក្សាភិបាលអង្គការ ប្រូចិក ផ្ទូឈ័រ និងលោកស្រីស៊ូសាន សារ៉ានឌុនតារាហូលីវ៉ូដនិងជ័យលាភីអូស្ការ ដែលតែងតែជួយគាំទ្រ ពួកយើងជានិច្ច។ យើងបានរៀបចំកម្មវិធីភោជនាអាហារសាមគ្គី និងល្បែងកំសាន្តផ្សេងៗ ជូនបុគ្គលិក កុមារី និងភ្ញៀវកិត្តិយស ដើម្បីប្រារព្ធពិធី រាប់ថយក្រោយស្វាគមន៍ឆ្នាំថ្មី២០២៤។



# អំពីសកម្មភាពការងារយើង

កម្មវិធីស្នូលរបស់ អង្គការ អាហ្វេស៊ីប កម្ពុជា គឺស្តារនីតិសម្បទា អប់រំនិងបណ្តុះបណ្តាល លើកកម្ពស់សេដ្ឋកិច្ច (សមាហរណកម្ម) និងបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ។

## ស្តារនីតសម្បទា

### មណ្ឌល ទុំ ឪ

ជាកន្លែងព្យាបាលមួយ តាមរយៈការផ្តល់ជម្រកសុវត្ថិភាព អាហារ១ថ្ងៃ៣ពេល ការថែទាំ អាហារូបត្ថម្ភ ការពិនិត្យព្យាបាលសុខភាព ការពិគ្រោះចិត្តសង្គម និងជំនួយផ្នែកច្បាប់ ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍន៍សុខមាលភាពផ្លូវកាយ និងផ្លូវចិត្ត ដល់កុមារីរងគ្រោះដែលយើងធ្វើការជាមួយ។

### ហេតុអ្វីបានជាយើងធ្វើការងារនេះ?

មណ្ឌលទុំឪជាដំណាក់កាលដំបូង ក្នុងការធ្វើឱ្យកុមារីរងគ្រោះ និងងាយរងគ្រោះមានស្ថេរភាព ផុតពីទុក្ខកង្វល់ដែលពួកគាត់បានជួបប្រទះ ជាទូទៅពួកគាត់អាចទទួលបានបរិយាកាសសុវត្ថិភាព ជួបជាមួយបុគ្គលិកថែទាំ គ្រូពេទ្យ ចិត្តសាស្ត្រ បុគ្គលិកគាំពារផ្នែកច្បាប់ សមាជិកបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ កសាងទំនុកចិត្ត និងទំនាក់ទំនង។

### តើធ្វើឱ្យមានភាពខុសគ្នាអ្វីខ្លះ?

យើងបានផ្តល់ជម្រកសុវត្ថិភាព អាហារូបត្ថម្ភ សម្លៀកបំពាក់ និងគ្រឿងឧបភោគ-បរិភោគ ដល់កុមារីរងគ្រោះ និងងាយរងគ្រោះដោយអំពើហិង្សាផ្លូវភេទ ជួញដូរ រំលោភបំពាន ទាសភាព និងកេងប្រវ័ញ្ចផ្លូវភេទ នៅក្នុងមណ្ឌលទុំឪ។

### អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថា យើងនឹងផ្តល់ការថែទាំគ្រប់ជ្រុងជ្រោយដល់កុមារីចំនួន១១០នាក់ នៅមណ្ឌលទុំឪ ក្នុងនោះ៣០នាក់ជាកុមារីចូលថ្មីក្នុងឆ្នាំ២០២៣ និង៨០នាក់ទៀតនៅសល់ចុងគ្រាឆ្នាំ២០២២។

### លទ្ធផលយើងសម្រេចបាន

កុមារីចំនួន៩៤នាក់ បានទទួលការថែទាំគ្រប់ជ្រុងជ្រោយ ជម្រកសុវត្ថិភាព អាហារូបត្ថម្ភនៅមណ្ឌលទុំឪ។ ដោយ៣២នាក់(៣នាក់ទទួលចូលមណ្ឌលវិញដោយមូលហេតុហានិភ័យផ្សេងៗ)ចូលថ្មីក្នុងឆ្នាំ២០២៣ និង៦២នាក់សល់ចុងគ្រាឆ្នាំ២០២២ លទ្ធផលសម្រេចបានលើសផែនការចូលថ្មីចំនួន២នាក់។

### ប្រភពបញ្ជូនជនរងគ្រោះ

អាហ្វេស៊ីប បានកសាងបណ្តាញការងារជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(មន្ទីរ ស.អ.យ) អាជ្ញាធរមូលដ្ឋាន និងគីពាក់ព័ន្ធនៅតាមខេត្ត ជាប្រភពបញ្ជូនកុមារីរងគ្រោះមកទទួលសេវាស្តារនៅមណ្ឌលយើង។

## ស្ថិតយុវនារី-កុមារីចេញពីមណ្ឌល

- យុវនារី៤នាក់ បានស្តាររួច ទទួលអាហារូបករណ៍ជំនាញវិជ្ជាជីវៈ ស្នាក់នៅក្រៅមណ្ឌល។
- យុវនារី៣នាក់ បានប្រឡងមធ្យមសិក្សាទុតិយភូមិបន្តអាហារូបករណ៍ឧត្តមសិក្សាសកលវិទ្យាល័យ។
- កុមារី១៦នាក់ បានស្តាររួច ទទួលអាហារូបករណ៍ក្រោមឧត្តមសិក្សានៅក្រៅមណ្ឌលជាមួយគ្រួសារ។

## ស្ថិតយុវនារី-កុមារីទទួលការថែតាំបន្ត

- កុមារី៧១នាក់ បន្តទទួលការថែទាំពេញលេញ នៅក្នុងមណ្ឌលទុំ ឌី នៅចុងគ្រា ខែធ្នូ ឆ្នាំ២០២៣។

ការទទួលទេវតាឆ្នាំថ្មី



ធ្វើបុកល្ហុង



កុមារីញាំអាហារ



ពិធីប្រារព្ធបុណ្យភ្ជុំបិណ្ឌ គឺជាការឈប់សម្រាកដ៏សំខាន់បំផុតនៅប្រទេសកម្ពុជា កុមារីដែលមានសាច់ញាតិគ្រួសារ គឺពួកគេទៅលេងគ្រួសារសាច់ញាតិនៅតាមបណ្ដាសហគមន៍នាឱកាសដ៏ពិសេសនេះ ។ លោកស្រីស្ថាបនិក **ម៉ម សុម៉ាលី** បានដឹកនាំក្រុមការងារ នាំកុមារីដែលមិនមានគ្រួសារសាច់ញាតិ នៅកំសាន្តនៅក្រុងសៀមរាប គឺទស្សនាប្រាង្គប្រាសាទអង្គរវត្តរយៈពេល៤ថ្ងៃ។



# ផ្នែកថែទាំសុខភាព

ជនរងគ្រោះដោយការជួញដូរ រំលោភសេពសន្ថវៈ រំលោភបំពានផ្លូវភេទ ឬការកេងប្រវ័ញ្ចផ្លូវភេទ តែងតែជាប់នូវស្លាកស្នាមវិប្បដិសារិ និងការមាក់ងាយពីមជ្ឈដ្ឋានជុំវិញ ដែលជាកត្តាធ្វើឱ្យប៉ះបាល់ដល់ការអភិវឌ្ឍផ្លូវកាយ និងផ្លូវចិត្ត។ កុមារីទទួលបានការពិនិត្យ និងវាយតម្លៃសុខភាពទូទៅ នៅពេលពួកគាត់មកដល់មណ្ឌលភ្លាម និងផ្តល់ការពិនិត្យព្យាបាលបន្ត តាមតម្រូវការជាក់ស្តែងពីវេជ្ជបណ្ឌិតរបស់យើង។

## អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថា យើងនឹងផ្តល់ការថែទាំសុខភាព១០០%ដល់កុមារីចូលថ្មីចំនួន៣០នាក់ នៅមណ្ឌលទុំឌី និងផ្តល់ការពិនិត្យ ព្យាបាលបន្ត ដល់កុមារីចំនួន៨០នាក់ តាមតម្រូវការជាក់ស្តែងរបស់ករណីនីមួយៗ។

## លទ្ធផលយើងសម្រេចបាន

១០០%នៃកុមារីចូលថ្មីចំនួន៣២នាក់ នៅមណ្ឌលទុំឌីបានទទួលការពិនិត្យ វាយតម្លៃ និងព្យាបាលសុខភាព លើរោគសញ្ញាសំខាន់ៗ ដូចជា បាក់តេរីទ្វារមាស រលាកមាត់ស្បូន ដង្កូវស៊ីធ្មេញ និងរាគ។ កុមារីចំនួន១១៣នាក់បានទទួលការពិនត្យ និងព្យាបាលបន្តចំនួន១០៥៥ដង តាមតម្រូវការជាក់ស្តែង លើរោគសញ្ញាគ្រុនផ្តាសាយ រលាកបំពង់ក ជំងឺសើស្បែក ឈាមច្រមុះ និងការពិនិត្យព្យាបាលត្រចៀក នៅក្នុងឆ្នាំ២០២៣។ កុមារទទួលបានការថែទាំសុខភាពលើសពីផែនការរំពឹងទុក។

- កុមារីចំនួន៨៨នាក់ បានទទួលការចាក់វ៉ាក់សាំងជាតិ១១មុខ ដើម្បីបង្ការជំងឺមេរោគមហារីកមាត់ស្បូន (HPV) តេតាណូស កូវីដ-១៩ រលាកស្រោមខួរក្បាល ផ្តាសាយ និងថ្លើមប្រភេទបេ។
- កុមារីចំនួន៧៦នាក់ បានទទួលការពិនិត្យ ព្យាបាលសុខភាពមាត់ធ្មេញ ដោយសហការជាមួយអង្គការគ្រួសារ ពិភពលោក កម្ពុជា។២នាក់ទទួលការព្យាបាលកម្រិតធ្ងន់។
- កុមារីចំនួន៧២នាក់ បានទទួលការពិនិត្យ ព្យាបាល ថែទាំភ្នែក ត្រចៀក ច្រមុះ និងបំពង់ក (EENT) ដោយសហការជាមួយមជ្ឈមណ្ឌលវះកាត់កុមារ។១០នាក់ព្យាបាលកម្រិតដោយត្រូវពាក់វ៉ែនតាម៉្យោប។
- កុមារីចំនួន២១នាក់ បានធ្វើតេស្តឈាម CBC glycaemia និង Ag-Anti-HBS កុមារីចំនួន២០នាក់បានធ្វើតេស្តហ៊ីវ (HIV) ដោយស្ម័គ្រចិត្ត។
- កុមារីចំនួន១០ករណី ទទួលថ្នាំព្យាបាលជំងឺគំរាមកំហែងអាយុជីវិតធ្ងន់ធ្ងរ សង្គ្រោះបន្ទាន់និងសំរាកនៅមន្ទីរពេទ្យ។
- កុមារីចំនួន៥នាក់ បានទទួលថ្នាំព្យាបាលជំងឺថ្លើមប្រភេទ ចតអេក្វ និងធ្វើPCR។
- កុមារី៧៥នាក់ បានទទួលការអប់រំសុខភាពបឋម ស្តីពីជំងឺរលាក់ស្បែក ការឡើងកំដៅ និងការហូរឈាមច្រមុះ ។

ការថែទាំសុខភាពកុមារី



ការថែទាំសុខភាពមាត់ធ្មេញ



ការផ្តល់វ៉ាក់សាំងការពារ



## ផ្នែកថែទាំសុខភាពផ្លូវចិត្ត

យើងដឹងហើយថា ឥទ្ធិពលនៃផលប៉ះបាល់ផ្នែកសុខភាពផ្លូវចិត្ត គឺការបាក់ទឹកចិត្ត និងការផ្តាច់ទំនាក់ទំនង ដូច្នេះកម្មវិធីស្តារនីតិសម្បទា យើងផ្តោតលើការលើកទឹកចិត្ត និងការបង្កើតទំនាក់ទំនងថ្មីៗ ដល់កុមារីដែលយើងធ្វើជាមួយទាំងនៅក្នុងមណ្ឌល និងនៅតាមសហគមន៍។ ពេលពួកគាត់មកដល់មណ្ឌលភ្លាម បានទទួលការវាយតម្លៃសុខភាពផ្លូវចិត្ត ការព្យាបាលបន្ទាន់ និងការតាមដានសុខភាពជាបន្តបន្ទាប់តាមតម្រូវការជាក់ស្តែងពីបុគ្គលិកចិត្តវិទ្យារបស់យើង។

## អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថា១០០%នៃកុមារីរងគ្រោះចូលថ្មីចំនួន៣០នាក់ នឹងទទួលបានការវាយតម្លៃសុខភាពផ្លូវចិត្ត ពេលពួកគាត់ចូលមកដល់មណ្ឌលទុំឌី និងកុមារីចំនួន៦៦នាក់នឹងទទួលបានការតាមដាន និងព្យាបាលសុខភាពផ្លូវចិត្តតាមតម្រូវការជាក់ស្តែង។

## លទ្ធផលយើងសម្រេចបាន

១០០%នៃចំនួនកុមារីរងគ្រោះចូលថ្មីចំនួន៣២នាក់ នៅមណ្ឌលទុំឌី បានទទួលការវាយតម្លៃសុខភាពផ្លូវចិត្តទូទៅដែលមានរោគសញ្ញាពិបាកគេង សុបិន្តអាក្រក់ ធ្លាក់ទឹកចិត្ត ពិបាកផ្ចង់អារម្មណ៍និងនឹកផ្ទះ។ កុមារីចំនួន៩៩នាក់បានទទួលការតាមដាននិងព្យាបាលសុខភាពផ្លូវចិត្តតាមតម្រូវការជាក់ស្តែង។ ចំនួនកុមារីបានទទួលការពិគ្រោះយោបល់និងព្យាបាលសុខភាពផ្លូវចិត្តទទួលបានលទ្ធផលល្អ លើសផែនការយើងរំពឹងទុក។

- កុមារីចំនួន៨៨នាក់ បានទទួលការព្យាបាលសុខភាពផ្លូវចិត្ត តាមបែបសិល្បៈចំនួន២០វគ្គ។
- កុមារីចំនួន៨០នាក់ បានទទួលវគ្គបណ្តុះបណ្តាល ការជួយខ្លួនឯងបានចំនួន៣៣វគ្គ អំពីប្រធានបទផ្សេងៗដូចជាការឆ្លុះបញ្ចាំងខ្លួនឯង ការយល់ដឹងពីខ្លួនឯង ការគ្រប់គ្រងកំហឹង ការឱ្យតម្លៃជឿជាក់លើខ្លួនឯង នីតិវិធីតុលាការ ការនិយាយវិជ្ជមានអំពីខ្លួនឯង ការស្រឡាញ់ខ្លួនឯង ធ្វើជាមនុស្សមានមេត្តាធម៌ និងការបង្កើតទំនុកចិត្តខ្លួនឯង។

- កុមារីចំនួន៦១នាក់ បានទទួលការអប់រំសុខភាពផ្លូវចិត្ត និងការការពារបង្ការបឋម ចំនួន៤វគ្គ លើប្រធានបទ បច្ចេកទេសនៃការសំរាក ការគ្រប់គ្រងកំហឹង និងការអប់រំបែបចិត្តសាស្រ្តអំពីការបាក់ទឹកចិត្ត។
- កុមារីចំនួន៩៤នាក់ បានហ្វឹកហ្វឺន និងអនុវត្តយោគៈជាប្រចាំនៅចុងសប្តាហ៍បាន៥៣វគ្គ នៅមណ្ឌលទុំឌី។
- កុមារីចំនួន១៣នាក់ បានទទួលការពិគ្រោះយោបល់ចិត្តសង្គមនៅមុន អំឡុង និងក្រោយពេល ចូលឆ្លើយបំភ្លឺ និង ចូលរួមសវនការជំរះក្តីនៅតុលាការ។
- កុមារី៨នាក់ បានទទួលការពិគ្រោះយោបល់ចិត្តសង្គមនៅមុន អំឡុង និងក្រោយពេលទទួលចូលមណ្ឌលទុំឌី ។
- គ្រួសារកុមារីចំនួន៥គ្រួសារ បានទទួលការពិគ្រោះយោបល់ ក្នុងអំឡុងពេលដំណើរការនីតិវិធីច្បាប់ នៅដំណាក់កាលសាកសួរនិងសវនាការជំរះក្តីនៅតុលាការ។

វគ្គព្យាបាលតាមបែបសីល្បៈ



វគ្គក្រុមជួយខ្លួនឯង



សកម្មភាពសមាធិនៅថ្ងៃឧបោសថសីល



វគ្គអប់រំសុខភាពផ្លូវចិត្តបឋម និងការការពារបង្ការ



## ជំនួយនីតិកម្ម

បុគ្គលិកផ្នែកនីតិកម្មធានាថាគ្រប់ជនរងគ្រោះទាំងអស់ ដែលយើងធ្វើការជាមួយ ហើយពាក់ព័ន្ធនីតិវិធីច្បាប់ យើងផ្តល់ជំនួយផ្នែកច្បាប់ និងជាតំណាងតាមនីតិវិធីច្បាប់ ដោយធ្វើការសហការជិតស្និតជាមួយបណ្តាអង្គការ-ស្ថាប័នដៃគូផ្សេងៗ រៀបចំឯកសារផ្នែកច្បាប់ ដើម្បីឱ្យជនសង្ស័យប្រឈមមុខចំពោះយុត្តិធម៌ និងធានាឱ្យបានថាជនរងគ្រោះទទួលបានការយកចិត្តទុកដាក់ដោយស្មើភាពចំពោះមុខច្បាប់ ។

## អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាកុមារីចំនួន៦០នាក់ ដែលពាក់ព័ន្ធនីតិវិធីច្បាប់ នឹងទទួលបានជំនួយផ្នែកច្បាប់ តាមនីតិវិធី។ ក្នុងនោះមាន៣០នាក់ ជាករណីចុងគ្រាឆ្នាំ២០២២ និង៣០នាក់ទៀត ជាករណីថ្មីពាក់ព័ន្ធច្បាប់ក្នុងឆ្នាំ២០២៣។

## លទ្ធផលយើងសម្រេចបាន

កុមារីចំនួន៦៣នាក់ បានទទួលជំនួយផ្នែកច្បាប់តាមនីតិវិធី។ ក្នុងនោះ៣៤នាក់ ជាករណីចុងគ្រាឆ្នាំ២០២២ និង២៩នាក់ ជាករណីថ្មីពាក់ព័ន្ធនីតិវិធីច្បាប់ក្នុងឆ្នាំ២០២៣ យើងសម្រេចលទ្ធផលលើសផែនការ។

- ជនសង្ស័យចំនួន៥៧នាក់ ត្រូវបានចាប់ឃុំខ្លួនឱ្យទទួលខុសត្រូវចំពោះមុខច្បាប់។ ក្នុងនោះ២០នាក់ ជាករណីចុងគ្រាឆ្នាំ២០២២ និង៣៧នាក់ជាករណីថ្មីត្រូវប៉ូលីសចាប់ឃុំខ្លួនក្នុងឆ្នាំ២០២៣។
- យើងបានស្នើសុំមេធាវីចំនួន២៦នាក់ ពីបណ្តាអង្គការ-ស្ថាប័នដៃគូ និងក្រុមមេធាវីស្ម័គ្រចិត្ត**សម្តេចតេជោ ហ៊ុន សែន** ដើម្បីការពារក្តី និងជាតំណាងជនរងគ្រោះតាមនីតិវិធីនៅតុលាការ។
- កុមារីចំនួន២៩នាក់ បានធ្វើកោសល្យវិច្ច័យ ជាភស្តុតាងដាក់បន្ទុកជនលើល្មើសចំពោះមុខច្បាប់នៅតុលាការ។
- កុមារី៤៣នាក់ បានចូលឆ្លើយបំភ្លឺ២៥ដង និងបានចូលរួមសវនាការជំរះក្តីចំនួន២៤ដងនៅតុលាការ( ករណីខ្លះលើសពី១ដង )។ ជនល្មើសចំនួន១៩នាក់ ត្រូវបានតុលាការផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ កម្រិតទោសទាប១៨ខែ និងខ្ពស់បំផុត១២ឆ្នាំ។ បង្គាប់សំណងរដ្ឋប្បវេណី៤ដល់៣២លានរៀល ប៉ុន្តែជនរងគ្រោះមិនដែលទទួលបានទេ។
- កុមារីចំនួន៥៥នាក់ បានទទួលការតាមដានជាមួយមេធាវី អំពីវឌ្ឍនភាពលើករណីរបស់ពួកគាត់ដែ លពាក់ព័ន្ធនីតិវិធីច្បាប់បានចំនួន៣១៧៦ដង ភាគច្រើនធ្វើការតាមដានតាមទូរស័ព្ទ។
- បានចូលរួមប្រជុំដោយផ្ទាល់ចំនួន២៧ដង និងទាក់ទងតាមទូរស័ព្ទចំនួន២១៩ដង ជាមួយមន្ត្រីសង្គមកិច្ច និងអាជ្ញាធរមូលដ្ឋាន អំពីការចុះទទួលកុមារីរងគ្រោះថ្មីចូលមណ្ឌល។

ការប្រជុំជាមួយអាជ្ញាធរពាក់ព័ន្ធពេលចុះទទួលកុមារីរងគ្រោះ

ការចូលរួមសវនាការនៅតុលាការ







## កម្មវិធីអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ

កុមារី-យុវនារីទទួលបានការអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជាក់លាក់មួយ ស្ថិតក្នុងបរិស្ថានសុវត្ថិភាព នៅតាមបណ្តាសាលារដ្ឋ និងសាលាវិជ្ជាជីវៈពិតប្រាកដសម្រាប់ជំនាញវិជ្ជាជីវៈ។ យើងបានដាក់ផែនការយុវនារី-កុមារីចំនួន **១៨៦**នាក់ នឹងទទួលបានការឧបត្ថម្ភការសិក្សាអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ តាមផែនការនៃប្រភេទនីមួយៗដូចខាងក្រោម។ ការអប់រំយើងផ្តល់ឱ្យពីថ្នាក់មត្តេយ្យ ដល់ឧត្តមសិក្សា នៅសកលវិទ្យាល័យតាមប្រភេទដូចតទៅ:

១. កុមារីចំនួន៧៥នាក់ នឹងទទួលបានអាហារូបករណ៍ ក្រោមឧត្តមសិក្សា ខណៈកំពុងស្នាក់នៅក្នុងមណ្ឌលទុំឌី។
២. កុមារីចំនួន៧៨នាក់ នឹងទទួលបានអាហារូបករណ៍ ក្រោមឧត្តមសិក្សា ស្នាក់នៅក្រៅមណ្ឌលជាមួយគ្រួសារ។
៣. យុវនារីចំនួន១៨នាក់ នឹងទទួលបានអាហារូបករណ៍ឧត្តមសិក្សា សកលវិទ្យាល័យ។
៤. យុវនារីចំនួន១៥នាក់ នឹងទទួលបានអាហារូបករណ៍ជំនាញវិជ្ជាជីវៈ។

### ហេតុអ្វីបានជាយើងធ្វើការងារនេះ?

ទិសដៅចំបងរបស់យើងគឺធ្វើឱ្យអ្នកទទួលផល សម្រេចបាននូវស្វ័យភាព ពិសេសគឺឯករាជ្យភាពហិរញ្ញវត្ថុ តាមរយៈការផ្តល់ឱកាសឱ្យពួកគាត់មានការងារធ្វើ ឬបង្កើតមុខរបរផ្ទាល់ខ្លួនក្រោយពេលបញ្ចប់ការសិក្សា។

### តើធ្វើឱ្យមានភាពខុសគ្នាអ្វីខ្លះ?

យុវនារី-កុមារីចំនួន១៩១នាក់ បានទទួលអាហារូបករណ៍ក្រោមឧត្តមសិក្សាខណៈស្នាក់នៅក្នុងមណ្ឌល អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌលជាមួយក្រុមគ្រួសារពួកគាត់ បន្ទាប់ពីបានស្តារ និងសមាហរណកម្មទៅតាមបណ្តាសហគមន៍វិញ នៅទូទាំងប្រទេសកម្ពុជា អាហារូបករណ៍ឧត្តមសិក្សាសកលវិទ្យាល័យ និងអាហារូបករណ៍ជំនាញវិជ្ជាជីវៈ។ លទ្ធផលសម្រេចបានលើសពីផែនការរំពឹងទុក។

- អាហារូបករណ៍ក្រោមឧត្តមសិក្សាចំនួន៨នាក់ បានប្រឡងជាប់មធ្យមសិក្សាបឋមភូមិជាស្ថាពរ។
- មានអាហារូបក្រោមឧត្តមសិក្សាចំនួន៧នាក់(២នាក់ស្ម័យរិន) បានប្រឡងមធ្យមសិក្សាទុតិយភូមិ(៣នាក់ជាប់)។

ថ្នាក់មត្តេយ្យក្នុងមណ្ឌល



ការតាមដានអាហារូបករណ៍ខាងក្រៅ



វិធីផ្តល់មេដាយនិងបណ្ណសសើរជូនសិស្សពូកែ



## អាហារូបករណ៍ក្រោមឧត្តមសិក្សាខណៈស្នាក់នៅក្នុងមណ្ឌល

### អ្វីយើងបាននិយាយថាយើងនឹងធ្វើ

ផែនការយើង កុមារីចំនួន**៧៥**នាក់ នឹងទទួលបានអាហារូបករណ៍ក្រោមឧត្តមសិក្សាខណៈស្នាក់នៅក្នុងមណ្ឌលទុំឌី។

### លទ្ធផលយើងសម្រេចបាន

កុមារី**៨៣**នាក់ បានទទួលអាហារូបករណ៍ក្រោមឧត្តមសិក្សា ខណៈស្នាក់នៅក្នុងមណ្ឌលទុំឌី។ ពួកគេទទួលបានឯកសណ្ឋានសិស្ស សម្ភារសិក្សា ប្រាក់ប្រចាំថ្ងៃសម្រាប់អាហារសម្រន់ មធ្យោបាយដឹកជញ្ជូនទៅ-មកសាលា ការចុះឈ្មោះចូលរៀន ការតាមដានបន្ត និងការឧបត្ថម្ភផ្សេងៗតាមតម្រូវការជាក់ស្តែង។ ស្ថិតិបញ្ជូនចេញពីមណ្ឌល៖

- ១នាក់ បានប្រឡងមធ្យមសិក្សាទុតិយភូមិ បន្តអាហារូបករណ៍ឧត្តមសិក្សាសកលវិទ្យាល័យ។
- ១នាក់ បានបញ្ជូនទៅទទួលអាហារូបករណ៍ជំនាញវិជ្ជជីវៈផ្នែកសម្អាងកាយ។
- ៩នាក់ បានសមាហរណកម្មទៅគ្រួសារ បានឧបត្ថម្ភអាហារូបករណ៍ក្រោមឧត្តមសិក្សា ស្នាក់នៅក្រៅមណ្ឌល។
- ៧២នាក់ កំពុងបន្តអាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្នុងមណ្ឌល។

ផ្តល់បណ្តុសសើរដល់សិស្សពូកែ



ផ្តល់ឯកសណ្ឋាន និងសម្ភារសិក្សា



កុមារីសិក្សានៅសាលរដ្ឋ



- បានបង្កើតក្រុមមិត្តសិក្សាចំនួន៩ក្រុម ជ្រើសរើសសិស្សពូកែនៅកម្រិតបឋម និងវិទ្យាល័យ ជួយបង្រៀនសិស្សរៀនខ្សោយ។ ៦ក្រុម បង្រៀនសិស្សបឋម៤៥នាក់ និង៣ក្រុមទៀត បង្រៀនសិស្សកម្រិតវិទ្យាល័យ២២នាក់។
- សិស្សអាហារូបករណ៍ក្រោមឧត្តមសិក្សា ស្នាក់នៅក្នុងមណ្ឌលចំនួន៩នាក់ ដែលសិក្សាថ្នាក់៦ ៩ និង១២ បានទទួលការរៀនបន្ថែមម៉ោង។ ក្នុងនោះ៥នាក់រៀនថ្នាក់ទី៦ ៣នាក់សិក្សាថ្នាក់ទី៩ និង១នាក់សិក្សាថ្នាក់ទី១២។
- កុមារី២០នាក់ បានទទួលជួយសម្របសម្រួលឯកសារចុះឈ្មោះចូលរៀន នៅតាមសាលាសារដ្ឋ។ ក្នុងនោះ១៣នាក់ជាអាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្នុងមណ្ឌល និង៧នាក់ជាទៀតសិស្សអាហារូបករណ៍ស្នាក់នៅក្រៅមណ្ឌល ដែលបានសមាហរណកម្មទៅគ្រួសារវិញបន្តការសិក្សានៅតាមសហគមន៍។

- បានប្រជុំប្រចាំខែចំនួន១០ដង ជាមួយសិស្សអាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្នុងមណ្ឌល ដើម្បីពិនិត្យតាមដាន លើវឌ្ឍនៈភាព នៃការសិក្សារបស់ពួកគាត់ នៅតាមសាលារដ្ឋ។
- បានផ្ដល់រង្វាន់លើកទឹកចិត្តដល់សិស្សពូកែចំនួន៣នាក់ ដែលបានខិតខំសិក្សាទទួលបាននិទ្ទេសល្អពីលេខ១ ដល់លេខ៣។ ក្នុងនោះ១នាក់ ជាសិស្សបឋម និង២នាក់ទៀត ជាសិស្សវិទ្យាល័យ។

## អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌល

### អ្វីយើងបាននិយាយថាយើងនឹងធ្វើ

កុមារីចំនួន**៧៨**នាក់ នឹងទទួលបានអាហារូបករណ៍ក្រោមឧត្តមសិក្សាខណៈស្នាក់នៅក្រៅមណ្ឌល ជាមួយគ្រួសារ បន្ទាប់ពីពួកគាត់បានស្តារនីតិសម្បទា។

### លទ្ធផលយើងសម្រេចបាន

កុមារី**៧៨**នាក់ បានទទួលអាហារូបករណ៍ក្រោមឧត្តមសិក្សា ស្នាក់នៅក្រៅមណ្ឌល ជាមួយគ្រួសារនៅតាមសហគមន៍ បន្ទាប់ពីពួកគាត់បានស្តារ បានទទួលឯកសណ្ឋានសិស្ស សម្ភារសិក្សា កង់សម្រាប់ជាមធ្យោបាយធ្វើដំណើរទៅសាលារៀន ការចុះឈ្មោះចូលរៀន ការតាមដានបន្ត និងការឧបត្ថម្ភផ្សេងៗតាមតម្រូវការជាក់ស្តែង។ ស្ថិតិចេញពីកម្មវិធី៖

- អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌលចំនួន៣នាក់ បានប្រឡងបញ្ចប់មធ្យមសិក្សាទុតិយភូមិ បន្តអាហារូបករណ៍ឧត្តមសិក្សា នៅសកលវិទ្យាល័យ។
- អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌលចំនួន៣នាក់ បានបោះបង់ការសិក្សា អង្គការបានជួយឱ្យពួកគាត់បង្កើតមុខរបរខ្នាតតូច ដើម្បីរកប្រាក់ចំណូលផ្គត់ផ្គង់ជីវភាពគ្រួសារ។
- អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌលចំនួន២នាក់ ត្រូវបានទទួលចូលមណ្ឌលវិញ ដោយមូលហេតុហានិភ័យផ្សេងៗ។
- អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌល៤នាក់ បានបោះបង់ការសិក្សាដោយមូលហេតុផ្សេងៗ
- ចុងគ្រាមានអាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌលជាមួយគ្រួសារ៦៦នាក់ កំពុងបន្តការសិក្សា
- អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌលចំនួន១២នាក់ បានទទួលការឧបត្ថម្ភកង់ម្នាក់១គ្រឿង
- អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌលចំនួន១១នាក់ សិក្សាថ្នាក់ទី៩ (៧នាក់) និងថ្នាក់ទី១២(៤នាក់) បានសិក្សាបន្ថែមម៉ោង ដោយយកប្រាក់ឧបត្ថម្ភប្រចាំខែរបស់សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចំណាយលើការរៀនគួនេះ។
- អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅចំនួន៦៩នាក់ បានទទួលការតាមដានបន្តចំនួន២៣៥ដង ពីក្រុមការងារកម្មវិធីអប់រំ និងបណ្តុះបណ្តាល។
- អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌលចំនួន៦៨នាក់ បានចាក់វ៉ាក់សាំងការពារកូវីដ-១៩។

ចែកសម្ភារសិក្សាដល់អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌល







## អាហារូបករណ៍ឧត្តមសិក្សាសកលវិទ្យាល័យ

### អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាយុវនារី**១៨**នាក់ នឹងទទួលអាហារូបករណ៍ឧត្តមសិក្សា សិក្សានៅតាមបណ្ដាសកលវិទ្យាល័យ។

### លទ្ធផលយើងសម្រេចបាន

យុវនារីចំនួន**២១**នាក់ បានទទួលអាហារូបករណ៍ឧត្តមសិក្សាសកលវិទ្យាល័យ បានសិក្សានៅតាមបណ្ដាសកលវិទ្យាល័យផ្សេងៗនៅក្នុងរាជធានីភ្នំពេញ។ ក្នុងនោះ១០សល់ចុងគ្រាឆ្នាំ២០២២ និង១១នាក់ទៀតជាសិស្សិតថ្មីក្នុងឆ្នាំ២០២៣។ លទ្ធផលសម្រេចបានច្រើនជាងផែនការ ដោយសារនិស្សិត៤នាក់ ក្នុងចំណោម២១នាក់ យើងគម្រោងនឹងឱ្យពួកគាត់ចូលរៀននៅដើមឆ្នាំ២០២៤ តែពួកគាត់បានចូលរៀនមុនផែនការនៅចុងឆ្នាំ២០២៣ បន្ទាប់ពីពួកគាត់បានប្រឡងបញ្ចប់មធ្យមសិក្សាទុតិយភូមិថ្នាក់ទី១២រួច។

និស្សិតអាហារូបករណ៍ទាំងអស់ ដែលកំពុងសិក្សាឆ្នាំទី១ និង២ត្រូវស្នាក់នៅក្នុងមណ្ឌល ហើយចាប់ពីឆ្នាំទី៣ឡើងទៅត្រូវចេញទៅស្នាក់នៅខាងក្រៅ ដើម្បីចាប់ផ្ដើមរស់នៅឯករាជ្យដោយខ្លួនឯង និងអាចចាប់ផ្ដើមស្វែងរកការហាត់ការ ឬការងារក្រៅម៉ោង ដើម្បីឱ្យមានបទពិសោធន៍ការងារ និងរកប្រាក់ចំណូលបានខ្លះ។ ក្នុងអំឡុងពេលពួកគាត់ស្នាក់នៅក្នុងមណ្ឌល ពួកគាត់ចាប់ផ្ដើមផ្ដល់ឱ្យសង្គមវិញខ្លះៗ តាមរយៈការជួយការងារក្នុងមណ្ឌលនៅក្រៅម៉ោងសិក្សារបស់ពួកគាត់។ **សម្ដេច តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា លោកបានផ្ដល់ការឧបត្ថម្ភអាហារូបករណ៍បង់ថ្លៃសាលាដល់និស្សិតឧត្តមសិក្សាទាំងអស់ រីឯអង្គការ អាហ្វេស៊ីប កម្ពុជា យើងបានផ្ដល់ការឧបត្ថម្ភការរស់នៅប្រចាំខែ ការសិក្សាភាសាអង់គ្លេសនិងកុំព្យូទ័រ កុំព្យូទ័រយួរដៃ១នាក់១គ្រឿងសម្រាប់ជំនួយដល់ការសិក្សា ការថែទាំសុខភាព សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន វគ្គបណ្ដុះបណ្ដាលខ្លីអំពីរបៀបសរសេរប្រវត្តិរូប និងក្របលិខិតចូលបម្រើការងារ និងចំណេះដឹងបឋមអំពីការចាត់ចែងលុយកាក់។ ស្ថិតិចេញពីកម្មវិធី៖

- និស្សិត៥នាក់ បានបញ្ចប់ការសិក្សាដោយជោគជ័យ បរិញ្ញាបត្រនីតិសាស្រ្ត រដ្ឋបាលសាធារណៈ ទីផ្សារនិងទំនាក់ទំនង នាយទាហានសកម្ម និងគ្រប់គ្រង មានការងារធ្វើពេញម៉ោងដោយប្រើប្រាស់ជំនាញបានសិក្សា។
- និស្សិតចំនួន១៦នាក់ កំពុងបន្តការសិក្សាថ្នាក់ឧត្តមសិក្សាសកលវិទ្យាល័យ នៅរាជធានីភ្នំពេញ។
- និស្សិតឧត្តមសិក្សា៩នាក់ បានទទួលកុំព្យូទ័រយួរដៃ១នាក់១គ្រឿងជាជំនួយការសិក្សារៀនសូត្ររបស់ពួកគាត់។
- និស្សិតអាហារូបករណ៍ឧត្តមសិក្សាចំនួន២១នាក់ បានទទួលការតាមដានបន្តចំនួន១៨៣ដង ពីក្រុមការងារកម្មវិធីអប់រំនិងបណ្តុះបណ្តាល លើវឌ្ឍនភាពនៃការសិក្សា បញ្ហាសុខភាព និងបញ្ហាប្រឈមផ្សេងៗ។

វគ្គបណ្តុះបណ្តាលអំពីរបៀបសរសេរប្រវត្តិរូបចូលបំរើការងារ



ការស្វែងរកសាលាត្រៀមចូលសិក្សា



និស្សិតអាហារូបករណ៍សកលវិទ្យាល័យថតរូបជាមួយលោកស្រីស្ថាបនិក**ម៉ម សុម៉ាលី**



## អាហារូបករណ៍ជំនាញវិជ្ជាជីវៈ

### អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាយុវនារី១៥នាក់ នឹងទទួលអាហារូបករណ៍ជំនាញវិជ្ជាជីវៈ។

### លទ្ធផលយើងសម្រេចបាន

យុវនារីចំនួន៩នាក់ បានទទួលអាហារូបករណ៍ជំនាញវិជ្ជាជីវៈ។ យើងផ្តល់ការឧបត្ថម្ភអាហារូបករណ៍ជំនាញវិជ្ជាជីវៈដល់អ្នកមិនអាចសិក្សាចំណេះដឹងទូទៅនៅសាលារដ្ឋបានដោយមូលហេតុផ្សេងៗ។ យើងមិនមានផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនៅក្នុងមណ្ឌលទេ ប៉ុន្តែយើងបញ្ជូនពួកគាត់ ទៅសិក្សាជំនាញពួកគាត់ពេញចិត្ត នៅតាមសាលាវិជ្ជាជីវៈនៅខាងក្រៅមណ្ឌល។ យើងឧបត្ថម្ភថ្លៃសិក្សា សម្ភារសិក្សា ថ្លៃការរស់នៅប្រចាំខែ ការថែទាំសុខភាព ការពិគ្រោះយោបល់ និងការតម្រង់ទិសជួយដល់ការសម្រេចចិត្តរបស់ពួកគាត់។

- អាហារូបករណ៍ជំនាញវិជ្ជាជីវៈចំនួន៥នាក់ បានបញ្ចប់ការសិក្សាជំនាញវិជ្ជាជីវៈដោយជោគជ័យ។
- អាហារូបករណ៍ជំនាញវិជ្ជាជីវៈចំនួន៤នាក់ កំពុងបន្តការសិក្សាជំនាញដែលបានជ្រើសរើស។
- យើងបានចុះតាមដានការសិក្សារៀនសូត្រសិស្សអាហារូបករណ៍ជំនាញវិជ្ជាជីវៈទាំងអស់បានចំនួន២៧ដង។

សិស្សអាហារូបករណ៍ជំនាញវិជ្ជាជីវៈ








## ថ្នាក់ភាសាអង់គ្លេស

### អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាកុមារី៦៥នាក់ នឹងទទួលបានការសិក្សាភាសាអង់គ្លេស។

### លទ្ធផលយើងសម្រេចបាន

កុមារីចំនួន៧៧នាក់ បានសិក្សាភាសាអង់គ្លេស។ ៥៨នាក់ បានសិក្សាភាសាអង់គ្លេសតាមកម្រិតផ្សេងៗដូចជា សៀវភៅភាសាអង់គ្លេសបឋមបោះពុម្ពលើកទី៣ និងទី៤ ស៊ុបភ័រម៉ាញ(កម្រិតIII) លែត្សហ្គោកម្រិតII និងព្យញ្ជនៈអង់គ្លេស។

យើងផ្តល់ការសិក្សាភាសាអង់គ្លេសដល់កុមារីស្នាក់នៅក្នុងមណ្ឌល អនុលោមតាមការប្តូរវេនសាលាចំណេះដឹងទូទៅ កុមារីមួយចំនួនសិក្សាពេលព្រឹក និងមួយចំនួនទៀតសិក្សាពេលរសៀល។ លទ្ធផលសម្រេចបាននេះលើសពីផែនការរំពឹងទុក។ ការបង្រៀនភាសាអង់គ្លេសចែកចេញជា២ក្រុម កុមារីធំៗសិក្សាប្រចាំថ្ងៃ និងកុមារីតូចៗ(១៩នាក់ថ្នាក់មត្តេយ្យ) សិក្សាចុងសប្តាហ៍ បង្រៀនដោយអតីតជនរងគ្រោះ១នាក់ បានបញ្ចប់ការសិក្សាបរិញ្ញាបត្រផ្នែកភាសាអង់គ្លេស ។ ដោយសារបញ្ហាពេលវេលា យើងមិនអាចបង្រៀនកុមារីតូចរាល់ថ្ងៃបានទេ។

- ៨នាក់ បានទទួលបណ្ណសរសើរ។ ៣នាក់ជាសិស្សលែត្យហ្គោIII ៣នាក់ថ្នាក់ដំបូង និង២នាក់ ទៀតថ្នាក់បឋម។
- ២៤នាក់ បានបញ្ចប់ថ្នាក់លែត្យហ្គោIII(១៨) ស៊ុបភ័រម៉ាញ៣បន្តទៅថ្នាក់ដំបូង(៤) និងបន្តថ្នាក់បឋម(២)។
- ៣នាក់បានសមាហរណកម្មទៅគ្រួសារ ១នាក់បន្តឧត្តមសិក្សាសកលវិទ្យាល័យ និង៤៤នាក់ បន្តការសិក្សា ។

សកម្មភាបសិក្សាភាសាអង់គ្លេសនៅក្នុងមណ្ឌលទុំទឺ





## ថ្នាក់សិក្សាកុំព្យូទ័រ

### អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាកុមារី**៧០**នាក់ នឹងទទួលបានការសិក្សាកុំព្យូទ័រ។

### លទ្ធផលយើងសម្រេចបាន

កុមារី**៤៩**នាក់ សិក្សាកុំព្យូទ័រ កម្មវិធីវាយអត្ថបទភាសាខ្មែរ និងអង់គ្លេស អ៊ឹមអេសវើដ(MS Word) អាដឌ័បហ្វូតូសប (Adobe Photoshop) អាដឌ័បហ្លាស់(Adobe Flash) អ៊ីនធឺណែតនិងអ៊ីម៉ែល និងអានីមេសឺន ធូឌី។ ៤នាក់ បានសមាហរណកម្មទៅគ្រួសារនៅតាមសហគមន៍ និង៤៥នាក់បន្តការសិក្សា។ ការសិក្សាកុំព្យូទ័រនៅក្នុងមណ្ឌល ប្តូរវេនតាមសិក្សាចំណេះដឹងទូទៅនៅសាលារដ្ឋ កុមារីមួយចំនួនសិក្សាពេលព្រឹក និងមួយចំនួនទៀតពេលរសៀល។ លទ្ធផលសម្រេចបានតិចជាងផែនការរំពឹងទុក ព្រោះបញ្ហាពេលវេលា(សាលារដ្ឋ) ខ្វះធនធាន យើងផ្តោតលើការបង្រៀនកុមារីធំជាងតូចៗ៖

- ២៩នាក់ បានបញ្ចប់ការសិក្សា កម្មវិធីអ៊ឹមអេសវើដ (១០) អ៊ិចសែលនិងផាវវ៉ើផុញ (១១) អាដូប ហ្វូតូសប (៥នាក់) និងអាដូប ហ្លាស់ (៣) បានទទួលវិញ្ញាបនបត្របញ្ជាក់ការសិក្សា។
- ១៤នាក់ សិស្សពូកែកម្មវីធីអាដូប ហ្លាស់ (៣) អ៊ិចសែល(៣) ហ្វូតូសប (៣) និងក្រុមមិត្តជួយមិត្ត(៥)បានទទួលលិខិតសរសើរនិងអំណោយ។
- បានកែលម្អថ្នាក់កុំព្យូទ័រ លាបថ្នាំថ្មី ប្តូរសរប្រផេះ ទៅពណ៌បៃតងខ្ចី ដើម្បីការពារភ្នែកកុមារីពីការចាំងផ្លាតពន្លឺព្រះអាទិត្យចូលទៅក្នុងថ្នាក់និងបានតុបតែងឱ្យមានភាពទាក់ទាញជាងមុន។

សកម្មភាពសិក្សាកុំព្យូទ័រនៅក្នុងមណ្ឌលទុំឌី





## បណ្ណាល័យ

### អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាកុមារី៨០នាក់ នឹងចូលអានសៀវភៅ និងធនធានសិក្សាផ្សេងៗ នៅក្នុងបណ្ណាល័យ មណ្ឌលទុំឌី។

### លទ្ធផលយើងសម្រេចបាន

មានកុមារីចំនួន៨១នាក់ បានចូលអានសៀវភៅ និងធនធានសិក្សាផ្សេងៗនៅក្នុងបណ្ណាល័យ មណ្ឌលទុំឌី។



## កម្មវិធីលើកកម្ពស់សេដ្ឋកិច្ច

ទិសដៅសំខាន់សម្រាប់យុវនារី-កុមារីម្នាក់ៗ គឺសម្រេចឱ្យបានស្វ័យឯករាជ្យភាព។ នៅដំណាក់កាលនេះ ពួកគាត់ដែលទទួលផលពីកម្មវិធី គឺបានកាត់បន្ថយការពឹងផ្អែកលើអង្គការអាហ្វេស៊ីប ព្រោះពួកគាត់អាចមានលទ្ធភាពផ្តល់ឱ្យសង្គមវិញខ្លះៗ តាមរយៈការជួយដល់យុវនារី-កុមារីដទៃទៀត ដែលកំពុងឆ្ពោះមកកាន់ដំណាក់កាលនេះដែរ។ នៅពេលយុវនារី-កុមារីមានវឌ្ឍនភាពលើការស្តារ អប់រំ និងបណ្តុះបណ្តាល យើងចាប់ផ្តើមនីតិវិធី ធ្វើសមាហរណកម្មពួកគាត់ទៅរស់នៅតាមសហគមន៍ធម្មតាវិញ ក្នុងន័យនេះគឺពួកគាត់ធ្វើជាកូនជាង ឬហាត់ការ ឬបង្កើតមុខរបរខ្លួនឯង។

### ហេតុអ្វីបានជាយើងធ្វើការងារនេះ?

យុវនារីចាប់ផ្តើមធ្វើការជាកូនជាង ឬហាត់ការ ឬបង្កើតមុខរបរខ្លួនឯង ដោយប្រើប្រាស់ជំនាញដែលពួកគាត់បានសិក្សាដើម្បីរកប្រាក់ចំណូល។ ពួកគាត់ចាប់ផ្តើមរៀនរស់នៅដោយឯករាជ្យ គ្រប់គ្រងថវិកានិងការចំណាយផ្សេងៗខ្លួនឯង ជាចំណុចចាប់ផ្តើមធ្វើឱ្យបានសម្រេចនូវឯករាជ្យភាពហិរញ្ញវត្ថុ តាមរយៈនិរន្តភាពអាជីព(មុខរបរ)។

### តើធ្វើឱ្យមានភាពខុសគ្នាអ្វីខ្លះ?

យុវនារីបានបញ្ចប់ការសិក្សាដោយជោគជ័យលើជំនាញបានជ្រើសរើស បានធ្វើសមាហរណកម្មឧបត្ថម្ភការងារ និងបង្កើតមុខរបរខ្នាតតូច ដោយប្រើប្រាស់ជំនាញបានសិក្សា ដើម្បីរកប្រាក់ចំណូលផ្គត់ផ្គង់ជីវភាពផ្ទាល់ខ្លួន និងក្រុមគ្រួសារ។ ពួកគាត់ចាប់ផ្តើមដំណើរការឯករជ្យភាពហិញ្ញវត្ថុ តាមរយៈដំណោះស្រាយនិរន្តរភាពមុខរបរ។

### អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាយុវនារី១៤នាក់ នឹងធ្វើសមាហរណកម្ម ឧបត្ថម្ភការងារនិងមុខរបរ ក្រោយពីបញ្ចប់ការសិក្សាដោយជោគជ័យលើជំនាញបានជ្រើសរើស។ យើងឧបត្ថម្ភបង្កើតមុខរបរ ចំពោះការធ្វើសមាហរណកម្មជាមួយបុខរបរខ្នាត់តូច និងឧបត្ថម្ភថ្លៃរស់នៅប្រចាំខែរយៈពេល៣ខែសម្រាប់សមាហរណកម្មជាមួយការងារប្រើប្រាស់ជំនាញដែលបានសិក្សារៀនសូត្រ។ យើងបន្តតាមដានយ៉ាទៀងទាត់លើ បញ្ហាសុខភាព ការពិគ្រោះយោបល់ចិត្តសង្គម ប្រឹក្សាបឋមលើមុខរបរនិងការងារ ផ្តល់ការឧបត្ថម្ភបន្ថែមក្រោយសមាហរណកម្មតាមតម្រូវការជាក់ស្តែងលើករណីនីមួយៗ។

សមាហរណកម្មដោយឧបត្ថម្ភមុខរបរខ្នាតតូច និងអាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌល





## លទ្ធផលយើងសម្រេចបាន

មានកុមារីចំនួន**១៦**នាក់ បានសមាហរណកម្មដោយឧបត្ថម្ភការងារ និងមុខរបរខ្នាតតូច។ ក្នុងនោះ៣នាក់បានសមាហរណកម្មជាមួយមុខរបរ និង១៣នាក់ ជាមួយការងារ។

- យុវនារី-កុមារី៧៦នាក់ បានទទួលការសួសុខទុក្ខគ្រួសារបានចំនួន១៣៨លើក។ ១២២លើក ជាការទៅលេងគ្រួសារនៅតាមសហគមន៍ និង១៦លើក គ្រួសារសាច់ញាតិមកលេងនៅមណ្ឌលទុំឌី។
- កុមារីចូលថ្មីចំនួន២៧នាក់ បានទទួលការរៀបចំផែនការអនាគត។
- យុវនារីសមាហរណកម្មសកម្ម៧៥នាក់ បានទទួលការតាមដានបន្ត២៨៥លើក ទាំងផ្ទាល់ និងតាមទូរស័ព្ទ។
- គ្រួសារកុមារីចំនួន២គ្រួសារ បានទទួលជំនួយឧបត្ថម្ភគ្រួសារ សម្រាប់ការថែទាំសុខភាព និងពង្រីកមុខរបរ។
- យុវនារីសមាហរណកម្មចំនួន៦នាក់ បានទទួលការឧបត្ថម្ភបន្ថែមក្រោយសមាហរណកម្ម សម្រាប់ការថែទាំសុខភាព(១នាក់) ពង្រីកមុខរបរ(៣នាក់) និងចង់ដៃអាពាហ៍ពិពាហ៍(២នាក់)។

## កម្មវិធីបណ្ដាញលើកកម្ពស់អតីតជនរងគ្រោះ (សែន)

***សែន***គឺជាការចងក្រងបណ្ដាញសមាជិក បានស្តារសះស្បើយពីរបួសផ្លូវកាយ ផ្លូវចិត្តដោយជោគជ័យ និងបានសមាហរណកម្មទៅតាមសហគមន៍វិញនៅទូទាំងប្រទេសកម្ពុជា ក្នុងគោលបំណងលើកទឹកចិត្ត និងសុខមាលភាពសង្គមដល់អតីតជនរងគ្រោះ បញ្ជ្រាប និងបង្កើនការយល់ដឹងដល់សាធារណៈជន ដើម្បីស្វែងរកដំណោះស្រាយឱ្យបានប្រសើរ។ សមាជិក***សែន***នីមួយៗដើរតួនាទីយ៉ាងសំខាន់ ជាអ្នកធ្វើការផ្លាស់ប្តូរនៅតាមសហគមន៍ពួកគាត់ តាមរយៈការពាំនាំសម្លេងជនរងគ្រោះ ស្វែងរកដំណោះស្រាយ។

### ហេតុអ្វីបានជាយើងធ្វើការងារនេះ?

កម្មវិធី***សែន***បានបញ្ចូលសហសម្លេងរបស់សមាជិកជាផែនការសកម្មភាពទិសដៅ ស្របតាមគោលដៅគន្លឹះ *“លើកទឹកជនរងគ្រោះ ឱ្យក្លាយជាអតីតជនរងគ្រោះ និងលើកទឹកចិត្តអតីតជនរងគ្រោះ ឱ្យក្លាយជាផ្នែកមួយ នៃដំណោះស្រាយ”*។ អតីតជនរងគ្រោះគឺជាអ្នកធ្វើការផ្លាស់ប្តូរដ៏ធ្មើមនៅក្នុងវិស័យការងារនេះ ពួកគាត់ជានិមិត្តរូប ដែលអាចឱ្យជនរងគ្រោះដទៃទៀត យកគំរូតាម នូវវីរភាពអង់អាចក្លាហានរបស់ពួកគាត់។

### តើធ្វើឱ្យមានភាពខុសគ្នាអ្វីខ្លះ?

សមាជិកនៃកម្មវិធីបណ្ដាញលើកកម្ពស់អតីតជនរងគ្រោះធ្វើកាងារ ជួយគាំទ្រដល់អ្នកទទួលផលពីកម្មវិធី ទាំងនៅក្នុងមណ្ឌលនិងនៅតាមសហគមន៍។

### អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាយើងនឹងជ្រើសរើសយុវនារី ទទួលចូលជាសមាជិកសែនចំនួន**៥៧**នាក់។

## លទ្ធផលយើងសម្រេចបាន

**សែន**មានសមាជិក**៥៩**នាក់។ ៣៧នាក់ ជាសមាជិកចុងគ្រាពីឆ្នាំមុនៗ និង២២នាក់ទៀតជាសមាជិកថ្មី។ យើងបាន រៀបចំប្រជុំអាហារសាមគ្គីជាមួយសមាជិក**សែន**បាន៣លើក ២លើកនៅរាជធានីភ្នំពេញ និង១លើកនៅខេត្តសៀមរាប ដើម្បីចែករំលែកបទពិសោធន៍ បញ្ហាប្រឈម បច្ចុប្បន្នភាពការងារ**សែន** និងពង្រឹងទំនាក់ទំនងសមាជិក។

- កុមារីបានបោះឆ្នោតប្រចាំឆ្នាំ១លើក ដោយសេរី យុត្តិធម៌ តាមឆន្ទៈពួកគាត់ ដើម្បីជ្រើសរើសប្រធានក្រុមដឹកនាំ ថ្មីជាតំណាងពួកគាត់ នៅមណ្ឌលទុំឌី។កុមារី៥នាក់ បានជាប់ឆ្នោតជាប្រធានក្រុមដឹកនាំ ។
- ១១៩នាក់ បានបន្តទទួលប្រាក់ឧបត្ថម្ភប្រចាំខែ ពី**សម្តេចនាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា។
- បានប្រជុំ១៦លើក ៤លើកជាមួយប្រធានក្រុមដឹកនាំ ដើម្បីគាំទ្រការអនុវត្តសកម្មភាពប្រចាំថ្ងៃពួកគាត់ និង១២ លើកជាមួយសមាជិក**សែន** ជាបុគ្គលិកកម្មវិធី និងកុមារីអំពីបញ្ហាទូទៅ ជួយដោះស្រាយបញ្ហាប្រឈមនានា។
- កុមារីចំនួន១៥០នាក់បានទទួលឪពុក-ម្តាយធម៌ តាមរយៈការគាំទ្រ ពីមូនិធិសូលីណា នៅប្រទេសស្វីស។

ពីធីប្រគល់វិញ្ញាបនបត្រនៃការបញ្ចប់ការសិក្សា៣ជំនាន់របស់សមាជិកកម្មវិធីបណ្តាញលើកម្ពស់អតីតជនរងគ្រោះ





ការបោះឆ្នោតប្រចាំឆ្នាំជ្រើសរើសប្រធានក្រុមដឹកនាំ



# អំពីបុគ្គលិក និងការគ្រប់គ្រងគម្រោង

## អំពីបុគ្គលិក

បុគ្គលិក៣៦នាក់ បម្រើការនៅអង្គការ អាហ្វេស៊ីប កម្ពុជា ក្នុងឆ្នាំ២០២៣ មាននារី២២ និងបុរស១៤នាក់។ ៨៤%នៃបុគ្គលិកនារីជាអតីតជនរងគ្រោះ។ យើងលើកទឹកអតីតជនរងគ្រោះ ឱ្យក្លាយជាផ្នែកមួយនៃដំណោះស្រាយ ព្រោះថាអតីតជនរងគ្រោះគឺជាអ្នកធ្វើការផ្លាស់ប្តូរដ៏ផ្ទើមនៅក្នុងវិស័យការងារនេះ ពួកគាត់ជានិមិត្តរូបឱ្យជនរងគ្រោះដទៃទៀតយកគំរូតាម នូវវីរភាពអង់អាចក្លាហានរបស់ពួកគាត់។ បុគ្គលិកជាអតីតជនរងគ្រោះ បច្ចុប្បន្នកំពុងកាន់តួនាទីការងារជាសមាជិកគណៈគ្រប់គ្រងជាន់ខ្ពស់ ដូចជាប្រធានកម្មវិធី **សេន** មណ្ឌល គិលានុបដ្ឋាយិកា អប់រំនិងបណ្តុះបណ្តាល អ្នកសម្របសម្រួលអាហារូបករណ៍ឧត្តមសិក្សានិងជំនាញវិជ្ជាជីវៈ ផ្នែកចិត្តសាស្ត្រ លើកកម្ពស់សេដ្ឋកិច្ច បុគ្គលិកថែទាំ ចុងភៅ ហិរញ្ញវត្ថុ អ្នកសម្របសម្រួលឪពុក-ម្តាយធម៌ ជំនួយការផ្នែកនីតិកម្ម ស្ថិតិនិងបញ្ចូលទិន្នន័យ។

## អំពីការគ្រប់គ្រងគម្រោង

យើងបានរៀបចំប្រជុំជាទៀងទាត់ ជាមួយបណ្តាប្រធានកម្មវិធី ក្នុងគោលបំណងចែករំលែក វឌ្ឍនភាពការងារ នៃកម្មវិធីនីមួយៗ ទទួលយកការឆ្លើយតបនៃការតាមដានការអនុវត្តសកម្មភាពការងារពីអង្គប្រជុំមុនៗ ទទួលយកបច្ចុប្បន្នភាពការ
ងារ បង្កើតក្រុមការងារ ឬផែនការសកម្មភាពការងារ តាមតម្រូវការជាក់ស្តែង លើសកម្មភាពជាក់លាក់ណាមួយ។ល។ នេះជាផ្នែកមួយនៃការកសាងស្មារតីក្រុមការងារ ការកសាងសមត្ថភាពបុគ្គលិក និងការគ្រប់គ្រងគម្រោងសម្រាប់បុគ្គលិក។ កម្មវិធីនីមួយៗបានប្រជុំជាមួយបុគ្គលិករបស់ខ្លួនក្នុងគោលបំណងដូចគ្នា។

ប្រធានកម្មវិធី-ផ្នែកនីមួយៗត្រូវធ្វើផែនការសកម្មភាពនិងថវិកាប្រចាំខែ សម្រាប់ការអនុវត្តសកម្មភាពការងារ អនុលោមតាមផែនការមេ ដាក់ជូនប្រធានខ្សែបណ្តោយពិនិត្យសម្រេច នៅរាល់ថ្ងៃទី២៥នៃខែនីមួយៗ និងធ្វើរបាយការណ៍សកម្មភាពការងារបានអនុវត្តដាក់ជូនប្រធានខ្សែបណ្តោយជារៀងរាល់សប្តាហ៍ទី១នៃខែបន្ទាប់។ ប្តាហ៍ទី៤ប្រចាំខែ បុគ្គលិកកម្មវិធី-ផ្នែកនីមួយៗត្រូវធ្វើបច្ចុប្បន្នភាពកំណត់ត្រាការងារ ចូលក្នុងសំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារីនីមួយៗ ដើម្បីបញ្ចូលទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រ សម្រាប់ធ្វើរបាយការណ៍ផ្ទៃក្នុង និងរបាយការណ៍ធ្វើចេញក្រៅ។



## ការកសាងសមត្ថភាពបុគ្គលិក

យើងបានផ្ដល់ការកសាងសមត្ថភាពបុគ្គលិក តាមរយៈវគ្គបណ្ដុះបណ្ដាលខ្លីៗរួមមាន អាកាប្បកិរិយានៃការបង្កគ្រោះថ្នាក់នៃការរួមភេទរបស់កុមារ (២នាក់) ការគាំពារកុមារដោយបរិយាបន្ន(៥នាក់) គំនិតផ្ដួចផ្ដើមសេរីភាពសហគមន៍-ជានាបានការចូលរួមផ្នែកសង្គមនិងសេដ្ឋកិច្ចដ៏សំខាន់(អនឡាញ)៣នាក់) KPMG Key Updates on New LoT និង VAT on E-commerce (អនឡាញ)៣នាក់) ការសង្គ្រោះផ្លូវចិត្តបឋម (២៦នាក់) និងអំណានភាសាអង់គ្លេស(១)

ថ្ងៃទី១៣-១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ យើងបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ប្រចាំឆ្នាំ ដើម្បីពិនិត្យលើវឌ្ឍនភាពកម្មវិធីឆ្នាំ២០២៣ និងអភិវឌ្ឍផែនការសកម្មភាពឆ្នាំ២០២៤របស់កម្មវិធីនីមួយៗ នៅមណ្ឌលទុំឱ រាជធានីភ្នំពេញ។

លទ្ធផលសម្រេចបានខាង អនុលោមតាមចក្ខុវិស័យ និងទិសដៅស្នូលថែងថា ផ្ដល់ការថែទាំ និងធានាបាននូវសិទ្ធិយុវនារី-កុមារីរងគ្រោះ និងងាយរងគ្រោះ ដោយអំពើទាសភាព តាមរយៈការស្តារ ការអប់រំ បណ្ដុះបណ្ដាល និងសមាហរណកម្មដោយជោគជ័យ ត្រឡប់ទៅសង្គមវិញ ដោយឯករាជ្យភាពហិរញ្ញវត្ថុ និរន្តរភាព និងភាពថ្លៃប្រឌិត។ យើងអនុវត្តការងារនេះ ដោយជួយជ្រោមជ្រែង និងបង្ហាត់បង្រៀនពួកគាត់ អំពីឯករាជ្យភាពហិរញ្ញវត្ថុ តាមរយៈនិរន្តភាពមុខរបរ។ បន្ទាប់មកយើងស្វាគមន៍ លើកទឹកចិត្តឱ្យពួកគាត់ ក្លាយជាផ្នែកមួយរបស់បណ្ដាញលើកកម្ពស់អតីតៈជនរងគ្រោះ ។

## ផែនការសកម្មភាព ឆ្នាំ២០២៤

- កុមារី១០៦នាក់ នឹងទទួលសេវាស្តារ ជម្រកសុវត្ថិភាព អាហារូបបឋម ថែទាំសុខភាព ពិគ្រោះយោបល់ចិត្តសង្គម និងជំនួនផ្នែកច្បាប់ នៅមណ្ឌលទុំឱ ឆ្នាំ២០២៤។ ៧៦នាក់ ស្ថិតិចុងគ្រាឆ្នាំ២០២៣ និង៣០នាក់ ទៀតកុមារីចូលថ្មី។
- បន្តតាមដានការអនុវត្តនីតិវិធីព្រហ្មទណ្ឌចំពោះអនិតិជនរងគ្រោះមានអាយុក្រោម១០ឆ្នាំ មិនគួចូលរួមសវនការនៅតុលាការ(នីតិវិធីក្រសួងយុត្តិធម៌)។
- យុវនារី-កុមារីចំនួន២០៣នាក់ នឹងទទួលបានអាហារូបករណ៍ក្រោមឧត្តមសិក្សា អាហារូបករណ៍ឧត្តមសិក្សាសកលវិទ្យាល័យ និងអាហារូបករណ៍ជំនាញវិជ្ជាជីវៈ។
- យុវនារីបានស្តារចំនួន៣២នាក់ នឹងសមាហរណកម្មឧបត្ថម្ភការងារ មុខរបរខ្នាត់តូច និងទៅគ្រួសាររបស់ពួកគាត់វិញ នៅតាមសហគមន៍។
- សមាជិកនៃបណ្ដាញលើកកម្ពស់អតីតជនរងគ្រោះចំនួន៧៩នាក់ នឹងជួយគាំទ្រការងារផ្សេងៗរបស់យើង ទាំងនៅក្នុងមណ្ឌលនិងសហគមន៍។ ក្នុងនោះ២០នាក់ជាសមជិកចូលថ្មី។
- វគ្គបណ្ដុះបណ្ដាលកសាងសមត្ថភាពបុគ្គលិកអំពីការរៀបចំចំណីអាហារូបបឋមសម្រាប់ចុងភៅ(អនុសាសន៍ពីការធ្វើអធិការកិច្ច) ទស្សនកិច្ចសិក្សាសម្រាប់កម្មវិធីមណ្ឌលនិងសុខភាព ជំនួយស្មារតីបុគ្គលិកចិត្តសាស្រ្ត១២ជំនួប ការថែទាំសុខភាពផ្លូវចិត្ត អន្តរាគមន៍ជាក្រុម៦វគ្គដល់បុគ្គលិកបានទទួលការបណ្ដុះបណ្ដាលការសង្គ្រោសុខភាពផ្លូវចិត្តបឋមពីស៊ីត្រូ នៅឆ្នាំ២០២៣ គរុកោសល្យ ភាពជាអ្នកដឹកនាំនិងការនិយាយសាធារណៈ។

# ក្រុមប្រឹក្សាភិបាល



**លោក ក្លូដ ហីលដែនប្រែន្ឌ**

ប្រធានក្រុមប្រឹក្សាភិបាល
អនុប្រធាន មូលនិធិសូលីណា
ស្ថាបនិកក្រុមហ៊ុន វីនី & វីនី ហ្សា



**លោកស្រីម៉ម សុម៉ាលី**

សមាជិកក្រុមប្រឹក្សាភិបាល
សកម្មជនសិទ្ធិមនុស្ស
ស្ថាបនិក និងអគ្គយិកា អាហ្វេស៊ីប



**លោក ឆានឌូ ប៊ីនឌី**

សមាជិកក្រុមប្រឹក្សាភិបាល
ប្រធានប្រតិបត្តិករធនាគារ ទីក្រុង
ស៊ីដនី ប្រទេសអូស្ត្រាលី និង
សមាជិកជាក្រុមប្រឹក្សាភិបាលអង្គ
ការ ប្រូចិក ផ្លូឈ័រ



**លោកស្រី អ៊ាន់ ស៊ីណា**

សមាជិកក្រុមប្រឹក្សាភិបាល
សកម្មជនសិទ្ធិមនុស្ស
សហនាយិកាកម្មវិធី
ប្រធានកម្មវិធីអតីតជនរងគ្រោះ



**ក. អាណាលីន ម៉ខ័ដ**

សមាជិកក្រុមប្រឹក្សាភិបាល
តារាសម្តែងហូលីវ៉ូដ សកម្មជនសិទ្ធិ
មនុស្ស និងស្ថាបនិកព្យុះស្នេហ៍

# សង្ខេបមូលនិធិទទួលបាន និងការចំណាយ

(មុនធ្វើសវនកម្ម)

| មូលនិធិទទួលបាន | |
|---|---|
| ម្ចាស់មូលនិធិ | សរុប(ដុល្លារអាមេរិក) |
| មូលនិធិសូលីណា ( Solyna Foundation ) | ១៦០,០៦០.០០ |
| គម្រោងអនាគត ( Project Futures ) | ១៥០,៩៥៩.៥៦ |
| មូលនិធិអ័រហ្វេនស្តាហ្វិស ( Orphanages Starfish Foundation ) | ២០,៩២៥.០០ |
| រាជរដ្ឋាភិបាលកម្ពុជា ( Royal Government of Cambodia ) | ១៤៧,៨៩២.១៨ |
| ក្រុមហ៊ុនសម្រស់ធម្មជាតិ ( Natural Beauty Co.Ltd ) | ៥១,០០០.០០ |
| សប្បុរសជន/តាមអនឡាញ ( Individuals/ Online ) | ៦១,៧៤៥.២១ |
| សរុប | ៥៩២,៥៨១.៩៥ |

| ការចំណាយតាមកម្មវិធី | មករា-ធ្នូ ២០២៣ | |
|---|---|---|
| | ដុល្លារអាមេរិក($) | % |
| កម្មវិធីស្តារនីតិសម្បទា | ៣១៧,៦៦៩.៧៥ | ៥២% |
| កម្មវិធីអប់រំនិងបណ្តុះបណ្តាល | ១០៧,០៣១.៣៥ | ១៨% |
| កម្មវិធីសមាហរណកម្ម | ៤៣,១៩១.៦៣ | ៧% |
| កម្មវិធីសេន SEN (លើកកម្ពស់អតីតជនរងគ្រោះ) | ៧៦,៤៨២.៥៥ | ១៣% |
| រដ្ឋបាល | ៦៥,៤២៥.០៨ | ១១% |
| សរុប | ៦០៩,៨០០.៣៦ | |

# ម្ចាស់ជំនួយ

## រាជរដ្ឋាភិបាលកម្ពុជា

Foundation SOLYNA — Saving children from sexual traffic

PROJECT FUTURES — TRANSFORMING LIVES

CAMBODIAN RED CROSS

HEART MOTHERS — Sending love to child survivors of sex trafficking

សប្បុរសជន

THE ORPHANED STARFISH FOUNDATION

សម្រស់ធម្មជាតិ

DAUN PENH CAMBODIA GROUP

NH Finance Cambodia

THE CHURCH OF JESUS CHRIST OF LATTER-DAY SAINTS

## រាជរដ្ឋាភិបាលកម្ពុជាបន្តឧបត្ថម្ភ

- អង្ករ១៤,៤តោនសម្រាប់រយៈពេល១២ខែ។
- ២៤០,០០០,០០០.០០រៀលឧបត្ថម្ភម្ហូបប្រចាំថ្ងៃសម្រាប់រយៈពេល១២។
- ១៤២,៨០០,០០០.០០រៀលឧបត្ថម្ភប្រាក់ហោប៉ៅប្រចាំខែដល់កុមារី១១៩នាក់សម្រាប់រយៈពេល១២ខែ។
- ៥០,០០០.០០ដុល្លារអាមេរិកជួយប្រចាំឆ្នាំ សម្រាប់ចំណាយលើការខ្វះខាតផ្សេងៗរយៈពេល១២ខែ។
- ឧបត្ថម្ភអាហារូបករណ៍(ថ្លៃសាលា)ដល់និស្សិតឧត្តមសិក្សាសកលវិទ្យាល័យចំនួន២០នាក់
- បានផ្ដល់រ៉ឺម៉កកង់បី(ត្រីចក្រយានយន្ត)ថ្មីចំនួន២គ្រឿងសម្រាប់ដាមធ្យោបាយដឹកជញ្ជូនជូនកុមារីទៅសាលារៀន

